# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BBI0083**

សម្ភាសជាមួយឈ្មោះ សាំង ខុន ភេទ ស្រី អាយុ ៥៥ឆ្នាំ

មុខងារខ្មែរក្រហមៈ ធ្វើស្រែ

មុខងារបច្ចុប្បន្នៈ ធ្វើស្រែចំការ

មានស្រុកកំណើតនៅៈ ភូមិប៉ម ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ស សេងគា

០១:៣០:០២

៤៧ទំព័រ

សេងគា : បាទ!អញ្ចឹងជាដំបូងខ្ញុំបានណែនាំឈ្មោះខ្ញុំឲ្យមីងបានស្គាល់សិន បាទ!ខ្ញុំឈ្មោះសេងគា ខ្ញុំអ្នកស្រុកបាត់ដំបងនេះដែរទេមីងនៅស្រុកឯកភ្នំ ហើយខ្ញុំធ្វើនៅមជ្ឈមណ្ឌលកម្ពុជា នៅភ្នំពេញមីង ហើយម៉ោនេះគោលបំណងរបស់ខ្ញុំដូចខ្ញុំបានប្រាប់មីងមិញអញ្ចឹងថាខាង ខ្ញុំចង់បានឯកសាររបស់មីងកាលពីសម័យខ្មែរក្រហមទាក់ទងជាមួយមីង ឬក៏សម័យ មុនៗ មីងជួបហេតុការណ៍អីខ្លះ មានទុក្ខលំបាកយ៉ាងម៉េចខ្លះ ព្រោះអីយើងដឹងហើយ ថា មនុស្សម្នាក់ៗជួបបញ្ហារៀងៗខ្លួនកាលពីសម័យហ្នឹង មីងជួបផ្សេង ដូចមីងនៅខាង នោះមិញអញ្ចឹងខ្ញុំសួរគាត់ គាត់ថាគាត់អត់លំបាកអីសោះ ។

ខុន : ខ្ញុំដូចគាត់ដែល ឥឡូវខ្ញុំនិយាយប្រាប់អូនអញ្ចឹងទៅ ខ្ញុំចេញតាំងពី៧៤ ។

សេងគា : អ៊ូ!អញ្ចឹងមីង?

ខុន : ចា៎!ចេញពី៧៤ម៉ោចូលម៉ោនៅស្រុក ខាងស្រុកនៅកងស្រុកៗយើងដែល កាលហ្នឹង នៅស្រុកព្រៃកប្បាសអូន ។

សេងគា : អ៊ូ!តាកែវ?

ខុន : ចា៎!តាកែវហ្នឹង ប៉ុនកាលហ្នឹងគេដាក់ស្រុកនៅតាមតំបន់ទៅ ស្រុក៥៥អីអញ្ចឹងទៅអូន ឥឡូវយើងហៅតាកែវអញ្ចឹងទៅនៅព្រៃកប្បាស នៅស្រុកព្រៃកប្បាសហើយអុំចេញពី ៧៤ម៉ោធ្វើកងនៅក្នុងកងស្រុក រួចពីកងស្រុកម៉ោក៏អុំអត់ជួបប្រទះអីលំបាកដែរ ការលំបាកវេទនាមិនសូវជួបប្រទះអីប៉ុន្មានទេ ការងារដូចវាស្រួលស្រោលនឹងធ្វើដែរ ហើយ នឹងការស្ម័គ្រចិត្តរបស់យើងដែរ ។

សេងគា ៖ បាទ!អញ្ចឹងខ្ញុំសុំការអនុញ្ញាតយកបទសម្ភាសន៍របស់មីងនេះទៅប្រើប្រាស់ដូច ខ្ញុំបាន បង្ហាញមីងអញ្ចឹង?

ខុន ៖ ចា៎!

សេងគា ៖ អញ្ចឹងអត់អីទេមីង?

ខុន ៖ ចា៎!

សេងគា ៖ បាទ!មីងអាយុប៉ុន្មានហើយ?

ខុន ៖ ខ្ញុំ៥០ជាងហើយ ខ្ញុំឆ្នាំរកា ប៉ុនមិនដឹង៥៦ឬ៥៥ ។

សេងគា ៖ បាទ!

ខុន ៖ ហើយដល់នេះវាមានការជួបការលំបាក ខ្ញុំម៉ោហើយខ្ញុំម៉ោនៅយើងជាមួយកងតាម៉ុក យើងហ្នឹង គាត់យកឡើងម៉ោឲ្យធ្វើជានារីស្រែអំបិល កាលហ្នឹងជួបប្រទះការលំបាកវា ម៉ាវត្តដែរ កាលពីយើងនៅផ្ទៃងនៅអី គ្រាប់ផ្លោងគ្រាប់អីធ្លាក់នៅទីកន្លែង ។

សេងគា ៖ មីងនៅជាមួយមីង សាន់ ស៊ីមដែរ?

ខុន ៖ ស៊ីមណាអូន?

សេងគា ៖ សាន ស៊ីមនៅកងស្រែអំបិលដែរ?

ខុន ៖ មិនដឹងម៉េចទាល់តែឃើញគ្នាបានស្គាល់ ព្រោះស្រែអំបិលវាមានស្រែអំបិលរដ្ឋ នឹង ស្រែអំបិលភាគ ។

សេងគា ៖ អ្ហូ!គាត់នៅស្រែអំបិលរដ្ឋ ។

ខុន ៖ ចា៎!ខ្ញុំនៅភាគ ដល់រួចម៉ោយើងនៅអញ្ចឹងយើងជួបប្រទះនឹងការលំបាកវាតិចតួចទេ ព្រោះកាលហ្នឹងខ្ញុំវានៅប៉ះនឹងកងការពារដែរ ហើយការលំបាករបស់ខ្ញុំវាពាក់កណ្ដាល លំបាក ពាក់កណ្ដាលស្រួលដូចគ្នាអូន ដល់នេះក៏ខ្ញុំឲ្យចាប់ពីស្រែអំបិលហ្នឹងម៉ោឃើញថា គេឲ្យឡើងធ្វើមេក្រុម ចា៎!ធ្វើមេក្រុមហើយក៏ម៉ោស្រែអំបិលហ្នឹងនៅយូរដែល តាំងពី ៧៤រហូតដល់៧៨ ប៉ុនគ្រាន់តែក្នុងនាមថានៅស្រែអំបិល ប៉ុនខ្ញុំនៅថាយើងចាត់ទុកថា ការពារនៅក្នុងអង្គភាពហ្នឹង ធ្វើកងការពារនៅស្រែអំបិលតាមឆ្នេរសមុទ្រហ្នឹង ប៉ុនថាខ្ញុំ វាអត់មានជួបការលំបាកទេ ដល់ទៅមុខបន្តិចទៀតបានមានជួបការលំបាក ដល់ពេល យើង៧៧ជិតចូល៧៨ហ្នឹងយួនបុកហើយ យួនបុកលកៗនៅខេត្តកំពតហ្នឹងម៉ង ដល់ បុកទៅយើងទៅទប់ទល់ជាមួយយួនហ្នឹងនៅលកនោះ អាហ្នឹងបានវេទនាកន្លែងហ្នឹងអូន វេទនាណាស់ឆ្លងកាត់គ្រាប់ផ្លោងឆ្លេងស្លាំអាហ្នឹងវេទនាមែន អត់បាយក្រហាយទឹក

កន្លែងហ្នឹងតែម៉ាវគ្គទេ អត់បាយចំនួន១ថ្ងៃ ២ថ្ងៃហ្នឹងអត់ទឹកអត់អីហ្នឹង នៅកន្លែងខេត្តកំពតហ្នឹង រួចពីហ្នឹងម៉ោអ៊ំឡើងម៉ោបាត់ដំបងនេះហើយ អាហ្នឹងនិយាយតាមវគ្គឃ្លាវ៉ាណាស់អូនណាស់ ចា៎! ឡើងម៉ោបាត់ដំបងនេះគេចាត់តាំងអ៊ំហ្នឹង ធ្វើជាប្រធាន សហករណ៍ ប្រធានសហករណ៍នៅឃុំបឹងស្រីពាក់ស្បែកយើងក្បែរបឹងក្រសាលនេះ ។

សេងគា : បន្តទៀត?

ខុន : ចា៎! ហើយក៏បានចុះដាប់ជាមួយប្រជាជនយើងចំនួនពីខែ៨រហូតដល់ ខែ១១នេះ អា ហ្នឹងបែកពីប្រជាជនហើយអាអូនណាស់ យើងបែកពីប្រជាជនម៉ោយួនបុកម៉ោៗ ឆ្នាំប៉ុន្មាននេះ បុកដំបូងចូលពេញប្រទេសកម្ពុជាយើងហ្នឹងអាហ្នឹងមិនដឹងឆ្នាំប៉ុន្មានទេ អ៊ំអត់ចាំឆ្នាំទេ ពី៧៩ហ្នឹងដែរអី ៧៩ហ្នឹងហើយអ៊ំចេញពីប្រជាជនហ្នឹងម៉ោមកចូល ទ័ពទៀតហើយ មកចូលកងវរថក្រោះ ម៉ោកងវរត់ក្រោះទៀតហើយ អង្គភាពទ័ពទៀត ហើយហ្នឹងនៅដឹកជញ្ជូនបាយឲ្យទ័ពនៅមុំស្តៅ ស្តៅនៅដងស្ទឹងយើងហ្នឹងអូន ដងស្ទឹងស្តៅអាដែងកោះ ក្រឡម៉ាជួរហ្នឹងភ្នំដេរហ្នឹងម៉ោ រួចម៉ោអ៊ំបាននៅស្នាក់ការបញ្ជូនអ្នករបួសទៀតទៅ ចេញពីហ្នឹងហើយអ៊ំជួបប្រទេះទៀតហើយ ជួបប្រទះរឿងគ្រាប់ផ្លោងគ្រាប់អីទៀត ហើយ ជួបប្រទះគ្រាប់ផ្លោងនៅណៃ៎ទួលប្រទេស ចេញពីណៃ៎បាណនយើងម៉ោ ហ្នឹង ហើយចេញពីបាណនម៉ោ ម៉ោស្តៅទៀតហើយៗម៉ោនៅភ្នំព្រាលយើងក្រញូងស្សាញ នេះអូន ចា៎! រួចម៉ោបានអ៊ំធ្លាក់ពីដីកម្ពុជាយើងម៉ោធ្លាក់ម៉ោដើរឆ្លងកាត់ភ្នំចុះភ្នំ ជាប់ តែ២-៣អាទិត្យដែរបានចូលម៉ោក្នុងថៃ នេះម៉ង ធ្លាក់ម៉ោក្នុងថៃហើយ បានមកដល់ថៃ ជួបប្រទះនឹងថៃក៏គេមិនចិត្តអាក្រក់ជាមួយខ្មែរយើងដែរ ប៉ុន្តែគ្រាន់តែគេណែនាំខ្មែរ យើងកុំឲ្យចេញចូលរហេតរហូតទេ ព្រោះកាលហ្នឹងគេថាគេគណបក្សវ៉ាច្រើនដែរ គណបក្សណាល្អគណបក្សណាអាក្រក់ បើបងប្អូនណាមានមាសមានប្រាក់អីកុំទុកដាក់ឆ្មេក ឆ្មាចខ្លាចក្រែងលបងប្អូនណាអាក្រក់អញ្ចឹងគេឃើញយើងគេវ៉ៃយើងចោលអញ្ចឹង ហើយក៏ខ្មែរយើងក៏ការពារបានមួយចំនួនធំដែរ អត់មានអ្នកណាចេញឆ្មេកឆ្មាចទេថៃគេ ឲ្យនៅម៉េចយើងនៅអញ្ចឹង ដល់រួចពីហ្នឹងម៉ោបានគេដឹកយើងពីចាន់សូរីហ្នឹងម៉ោៗគេ យកមកដាក់ខ្លែន៧៩ ដាក់ខ្លែនហ្នឹង នៅហ្នឹងវត្តខ្លែនថៃហ្នឹងម៉ាអាទិត្យរួចម៉ោបានគេ ចេញម៉ោនៅលែនយើងហ្នឹងទៀតហើយ ចា៎! ក្រវេះក្រវែលៗនៅហ្នឹងរួចម៉ោបានគេ ឲ្យយើងទៅនៅភ្នំត្រាងយើងនេះ កូនឯងស្គាល់នៅត្រាង?

សេងគា ៖ បាទ!

ខុន ៖ ចា៎! ទៅនៅគ្រាងហ្នឹងដឹកជញ្ជូនអាហ្នឹងដឹកជញ្ជូនទ័ពហើយ បានធ្វើកងនារីដឹកជញ្ជូនគ្រាប់ទៀតហើយកាល៧៩យួនចូលហ្នឹងអូនណាស់ ចូលហ្នឹងទៀតហើយ ឈប់នៅជាមួយទ័ពហើយចូលមកដឹកជញ្ជូនវិញម្តងហើយ ជួបប្រទះនឹងការវេទនាគ្រប់បែបយ៉ាងហើយ អត់បាយហូប អត់ទឹកហូបអីនឹងជួបហើយ ហើយនឹងគ្រុនចាញ់ហ្នឹង ជួបប្រទះនឹងគ្រុនចាញ់មួយថ្ងៃញាក់៧ដងក៏មាន ប៉ុនគ្រាន់តែយើងវាអត់ដាច់បាយដាច់អីនៅមានអង្ករមានអីបបរដាប់អញ្ចឹង មកជួបប្រទះប្រហែលជា២ខែខ្ញុំនោះ ជួបការលំបាកវេទនាប្រហែលជា២ខែហ្នឹងទេ រួចម៉ោក៏បានបងប្អូនយើងមេៗហ្នឹងទំនាក់ទនងអីជាមួយថៃជាមួយអីហ្នឹងទៅគេជួយឧបត្ថមជំនួយពីថៃម៉ោខ្លះ ពីចិនម៉ោខ្លះមិនដឹងទេជំនាន់ហ្នឹងគេមិនឲ្យដឹងអស់ទេយើងវា យើងវាឈប់យកចិត្តទុកដាក់អីអស់ហើយ ស្រេចតែមេៗ ហ្នឹងហើយក៏អុំចាប់ផ្តើមមានគ្រួសារមានអីទៅអាហ្នឹងនៅក្នុងវង្វង់គ្រួសារ អញ្ចឹងបានថាការលំបាករបស់អុំវាអត់សូវមានការលំបាកវែងម៉ាន់ដូចគេទេអូន ខ្លះគេននេលននេសអត់បាយអត់ទឹកអីច្រើនថ្ងៃច្រើនខែច្រើនឆ្នាំម៉ោណាស់ឈឺនៅតែ គឺនៅតែជីវិតនៅតក់ៗ ទេ អុំអត់អីទេ អុំដូចថាមានគេជួយគ្រប់បែបយ៉ាងអញ្ចឹង ហើយអន្តភាពយើង អន្ត ភាពខ្លះក៏វេទនា អន្តភាពខ្លះក៏គ្នាមិនសូវវេទនាដែរអូនណាស់ វាតាម ហ្នឹងសម័យកសាង ជំនាន់ពីមុនដែលថាកងចល័តគ្នាអត់បាយនោះណា៎ ហើយដូចថាអុំមិនបានឆ្លងកាត់ទេ ជំនាន់ខ្មែរក្រហមប៉ុល ពតហ្នឹងអត់មានជួបប្រទះអីវែង ម៉ាន់ទេតែម៉ាចំនួនតូចហ្នឹងទេ រហូតមកដល់បច្ចុប្បន្ននេះទៅអុំដូចរស់នៅម៉ាជុំ ខ្ញុំមិនសូវជួបការលំបាកអីប៉ុន្មានទេ ។

សេងគា ៖ បាទ! មុនដំបូងខ្ញុំចង់ស្គាល់ឈ្មោះអុំសិន?

ខុន ៖ ខ្ញុំឈ្មោះ សាំង ខុន ។

សេងគា ៖ ឈ្មោះអីអុំ?

ខុន ៖ ជីតាឈ្មោះ សាំង ខុន ។

សេងគា ៖ អាយុប៉ុន្មានហើយ?

ខុន ៖ ៥៥ ឆ្នាំរកា ។

សេងគា ៖ ស្រុកកំណើតនៅណា?

ខុន ៖ ស្រុកកំណើតនៅស្រុកព្រៃកប្បាស ភូមិ ។

សេងគា : ភូមិៗអីទេ?

ខុន : ភូមិប៉ម ។

សេងគា : ឃុំ?

ខុន : ឃុំក្ដាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

សេងគា : ចុះឥឡូវនៅភូមិអីដែរ?

ខុន : ឥឡូវនៅភូមិដូង ឃុំបឹងព្រាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។

សេងគា : ឪពុកមីងឈ្មោះអីដែរ?

ខុន : ឪពុកម្ដាយខ្ញុំគាត់ស្លាប់បាត់អស់ហើយ?

សេងគា : បាទ!ប៉ុនគាត់ឈ្មោះអីដែរ?

ខុន : ស្គាល់តែឈ្មោះគាត់ជីតាគាត់អត់ ឈ្មោះ ទូច ។

សេងគា : ឪពុកឈ្មោះទូច?

ខុន : ចាំ!

សេងគា : អត់ស្គាល់ត្រកូល?

ខុន : ត្រកូលបែបសាំងដែលហ្នឹង ។

សេងគា : បាទ!ម្ដាយ?

ខុន : ម្ដាយឈ្មោះ ម៉ែន ។

សេងគា : ឈ្មោះអីម៉ែន អត់ស្គាល់ត្រកូលទេ?

ខុន : អត់ ភ្លេចអស់អីកូនអើយតាំងពីតូចខ្ញុំម៉ោតាំងពីអាយុ១៧ ។

សេងគា : គាត់កាលសម័យណា?

ខុន : គាត់ស្លាប់យូរហើយ តាំងពីខ្ញុំអាយុ៩ឆ្នាំនោះហ្នឹងឪពុក បើម្ដាយខ្ញុំទឹមស្លាប់មុនយើងផ្ដាច់ខ្លួនខ្មែរក្រហមនេះទេ ស្លាប់បានប្រហែលកន្លះឆ្នាំនេះ ។

សេងគា : មីងមានកូនប៉ុន្មាននាក់ដែរ?

ខុន : ខ្ញុំមានកូន៨នាក់ ស្រីទាំង៨នាក់ ។

សេងគា : កូនទី១ឈ្មោះអីទៅ?

ខុន : ឈ្មោះ ចាន់ធី ។

សេងគា : ត្រកូលឈ្មោះ ចាន់?

ខុន : ឡាប ចាន់ធី ។

សេងគា ៖ ឡាច ចាន់ធី?

ខុន ៖ ចា៎!

សេងគា ៖ ចុះទី២?

ខុន ៖ ឡាច ចន្ធូ ។

សេងគា ៖ ចុះទី៣?

ខុន ៖ ទី៣ ឡាច គន្ធា ។

សេងគា ៖ ចុះទី៤?

ខុន ៖ ទី៤ ឡាច ចាន់ថុល ។

សេងគា ៖ ពួកគាត់ទាំង៤កើតទាន់សម័យប៉ុល ពតទេ?

ខុន ៖ កើតណែ៎ដែលយើងយួនចូលនេះនៅប៉ុល ពតនៅឡើយ ។

សេងគា ៖ ៧៩?

ខុន ៖ អត់ទេអូន កើតឆ្នាំដែល៨១អីហើយ ។

សេងគា ៖ មីងមានបងប្អូនប៉ុន្មាននាក់ដែរមីង?

ខុន ៖ ខ្ញុំមាន៥នាក់ដែរ ប៉ុនស្លាប់អស់ហើយអូនអើយនៅតែ២នាក់នៅរាល់ថ្ងៃ ស្រីទាំង៥ ដែរ ។

សេងគា ៖ ស្រីទាំង៥នាក់ដែរ?

ខុន ៖ ចា៎!

សេងគា ៖ មីងកូនទីប៉ុន្មាន?

ខុន ៖ ខ្ញុំកូនពៅគេបង្អស់ ។

សេងគា ៖ កូនបងទី១ឈ្មោះអី?

ខុន ៖ បងទី១បងនោះ?

សេងគា ៖ បាទ!

ខុន ៖ ឈ្មោះ ម៉ន ។

សេងគា ៖ ឈ្មោះ សាំង ម៉ន?

ខុន ៖ ចា៎!

សេងគា ៖ ចុះទី២?

ខុន ៖ ទី២ឈ្មោះ សាំង ឆេង ។

សេងគា ៖ ទី៣?

ខុន : ទី៣ សាំង ធន ។

សេងគា : ទី៤?

ខុន : ទី៤ សាំង ខន ។

សេងគា : ទី៥?

ខុន : ទី៥ សាំង ខុន ។

សេងគា : នៅសល់ប៉ុន្មាន សល់២នាក់?

ខុន : ស្លាប់អស់៣ហើយ នៅសល់តែ២នាក់ទេ ។

សេងគា : ស្លាប់អ្នកណាខ្លះ?

ខុន : ស្លាប់បងទី១ ហើយនឹងបងទី៣ នឹងបងទី៤ហ្នឹង នៅបងទី២ ហើយនឹងហ្នឹង ស្លាប់ជំនាន់ប៉ុល ពតហ្នឹង ស្លាប់ដោយវេទនាបំផុតហើយហ្នឹង អត់បាយអត់ថ្នាំពេទ្យ ។

សេងគា : បាទ!មុននឹងសួរទៅដល់រឿងសង្គ្រាម ខ្ញុំចង់ដឹងពីជីវប្រវត្តិរបស់មីងកាលនៅពីក្មេង?

ខុន : ចា៎!

សេងគា : កាលនៅពីក្មេងមីងចូលរៀននៅថ្នាក់ទីប៉ុន្មាន?

ខុន : អូនអើយដូចថាយើងវេទនា ដូចថាយើងទ័លក្រវេទនាណាស់ វាពោគេមែនពិត ប៉ុនទៅមើលក្មួយឡូ បងដែលទី១នេះ ។

សេងគា : អ៊ូ!អត់បានរៀនទេ?

ខុន : ចា៎!អត់បានរៀនគេទេអូន ។

សេងគា : កាលហ្នឹងអត់បានរៀនទាំងអស់ម៉ងមីង?

ខុន : ចា៎!អត់ម៉ង ។

សេងគា : ដល់ពេលឆ្នាំ៧០អ៊ីអាយុប៉ុន្មានហើយ កាលឆ្នាំ៧០កាល លន់ ណុល ធ្វើរដ្ឋប្រហារ?

ខុន : ចា៎!អាហ្នឹងខ្ញុំ ៧០ម៉ោ៧៤យើងវាអាយុ១៧ៗ អញ្ចឹងអាចអាយុ១៨ ព្រោះខ្ញុំចេញ៧៤អាយុ១៧ ។

សេងគា : បាទ!កាលហ្នឹងនៅកុមារនៅឡើយ?

ខុន : ចា៎!នៅកុមារនៅឡើយទេ ។

សេងគា : មីងចេញ៧៤?

ខុន : ចា៎!ខ្ញុំចេញ៧៤ ។

សេងគា : ម៉េចបានចេញពីផ្ទះ?

ខុន ៖ ខ្ញុំចង់ធ្វើ ខ្ញុំឃើញគេធ្វើទ័ពចង់ ។

សេងគា ៖ មីងចង់ធ្វើទ័ព?

ខុន ៖ ចា៎!

សេងគា ៖ ហើយបងមីងអត់មកធ្វើទ័ពជាមួយទេ?

ខុន ៖ អត់!ចង់ម៉ង អូនឯងចង់ម៉ង គេឃាត់ប្រធានភូមិប្រធានឃុំគេអត់ឲ្យចេញទេ ប៉ុន្តែនឹកឃើញថានៅក្នុងភូមិគេមើលងាយ នារីក្នុងភូមិអញ្ចឹង គេមើលងាយយើងនារីភូមិ ណាស់ អញ្ចឹងខ្ញុំសុខចិត្តថាចេញឲ្យផុតពីភូមិពីឃុំម៉ងទៅកុំឲ្យគេមើលងាយយើង ព្រោះកាលហ្នឹងនារីភូមិឃុំអី គេឃើញយើងនៅភូមិគេមិនសូវជាទទួលស្គាល់យើងប៉ុន្មានទេ គេចាំតែឲ្យយើងចេញឲ្យផុតៗដែរហ្នឹង ហើយខ្ញុំក៏ស្ម័គ្រចិត្តចេញម៉ង ព្ទសូរគេរើស៣០នាក់ដែលខ្ញុំក៏សុំចេញទៅ ស្ម័គ្រចិត្តដោយខ្លួនឯងម៉ង ដូចចង់ធ្វើទ័ព ។

សេងគា ៖ គេអត់ឲ្យធ្វើយ៉ាងម៉េចក៏នៅតែចង់ធ្វើដែរ?

ខុន ៖ ចា៎!នៅតែចង់ គេអត់ឲ្យទៅធ្វើ គេអត់ឲ្យទៅធ្វើខ្សែត្រៀមក៏ទៅ ។

សេងគា ៖ ដោយសារគេមើលងាយឬយ៉ាងម៉េច?

ខុន ៖ ចា៎!ដោយសារគេមើលងាយហើយ នឹកឃើញថ្នក់ចិត្តនឹកឃើញថាធ្វើទ័ពងាប់ទៅក៏មានន័យ កាលហ្នឹងយុទ្ធមិត្តគេស្លាប់មួយៗមានន័យណាស់ ។

សេងគា ៖ បាទ!ដល់អញ្ចឹងយើងមានអារម្មណ៍ថា?

ខុន ៖ ចា៎!យើងមានអារម្មណ៍ថាទោះស្លាប់ក៏មិនស្តាយ ។

សេងគា ៖ កាលហ្នឹងមីងធ្វើទ័ពនៅតាកែវ?

ខុន ៖ ចា៎!នៅតាកែវហ្នឹងនៅស្រុកហ្នឹង នៅម្តុំរវៃនៅតាកែវយើងដែរហ្នឹង ។

សេងគា ៖ នៅព្រៃកប្បាស?

ខុន ៖ ចា៎!នៅត្រៀមនៅម្តុំព្រៃថ្នាំ នៅម្តុំស្រែភាសនៅទល់ដែនតាកែវហ្នឹងម៉ង ។

សេងគា ៖ ស្រែភាស?

ខុន ៖ ចា៎!ស្រែភាសយើងនេះហ្នឹង ហើយយើងស្នាក់នៅៗណែ៎ ។

សេងគា ៖ ៧៤ អាយុ១៧ឆ្នាំហើយ?

ខុន ៖ ចា៎!អាយុ១៧ឆ្នាំ ចេញម៉ោហ្នឹង ។

សេងគា ៖ ស្ម័គ្រចិត្ត?

ខុន ៖ ចា៎!ស្ម័គ្រចិត្តម៉ងអត់មានគេចាប់បង្ខំអីទេ ។

សេង៉គា ៖ ធ្វើអី ធ្វើទ័ព?

ខុន ៖ ធ្វើទ័ពស្រុក ។

សេង៉គា ៖ ធ្វើទ័ពស្រុក?

ខុន ៖ ចា៎!ទ័ពស្រុក ។

សេង៉គា ៖ ម៉េចបានគេឲ្យធ្វើ មីង៉ឮគេរើស?

ខុន ៖ គេរើស ។

សេង៉គា ៖ អ្នកណាគេរើស?

ខុន ៖ សក្តិភូមិគេរើសម៉ោដូចថាអូនឯង ហ្នឹងឧទាហរណ៍ទេណា៎ ពីស្រុកម៉ោ ចុះម៉ោតាមឃុំ ហើយដល់ឃុំគេចុះម៉ោតាមភូមិ គេប្រាប់ភូមិថាឥឡូវក្នុងភូមិហ្នឹងគេសុំរើសនារី១៥-៦នាក់ អញ្ចឹងទៅអ្នកណាស្ម័គ្រចិត្តឬមួយបង្ខំអីអញ្ចឹង ខ្ញុំគ្រាន់តែឮថាគេរើសខ្ញុំសុំខ្លួន ខ្លួនឯងម៉ង់ចា៎! ហើយប្រធានភូមិប្រធានអីគេអត់ឲ្យខ្ញុំម៉ោទេ ចា៎!គេកុហកដែរហ្នឹងប៉ុន ខ្ញុំក៏នៅតែចង់ម៉ោៗស្ម័គ្រចិត្តដោយខ្លួនឯងហ្នឹងម៉ង់ ដល់ហើយគេឲ្យម៉ោនៅកងស្រុក កាន់កាំភ្លើងហាត់អីហ្នឹង ។

សេង៉គា ៖ គេរើសគ្នាប៉ុន្មាន៣០នាក់?

ខុន ៖ រើសបានតែប៉ុន្មាននាក់ទេអត់បានដល់៣០ទេ ។

សេង៉គា ៖ ប៉ុន្តែចំនួន៣០នាក់?

ខុន ៖ ចា៎!រើសចំនួន៣០នាក់ ប៉ុនបានតែ៤នាក់ទេ ម៉ាក្នុងវង្វង់អ្នករើសហ្នឹងបានតែ៤នាក់ ទេ ។

សេង៉គា ៖ ស្ម័គ្រចិត្តធ្វើទាហានឪពុកម្តាយមានហាមទេ?

ខុន ៖ ឪពុកម្តាយគាត់និយាយចេះដែរ គាត់ថាបើកូនឯងទៅហើយក៏ទៅចុះ ប៉ុនធ្វើម៉េចកូនឯងកុំវិលវិញឲ្យសោះ កុំថាឡើយកូនមួយកូនម៉ាចំហៀងក៏ម៉ែអត់ឲ្យនៅដែរ គាត់ឃើញថាយើងដូចថា យើងម៉ោធ្វើទ័ពអញ្ចឹងប្អូនណាស់ ពេលរត់ទៅវិញៗគេចាប់ចងចាប់អីដំរុញម៉ោវិញ ហើយគាត់ឃើញគេអញ្ចឹងគាត់ខ្លាចខ្ញុំហ្នឹងដូចគេអញ្ចឹងដែរ ។

សេង៉គា ៖ អ្ហ៊!

ខុន ៖ ចា៎!ខ្លាចយើងទ្រាំតស៊ូមិនបានការលំបាក ខ្លាចគ្រាប់ផ្លោងគ្រាប់កាំភ្លើងតូចកាំភ្លើងធំអីអញ្ចឹងទៅ រត់វិលទៅវិញអញ្ចឹងទៅ គេចាប់ចងយើងអញ្ចឹង ហើយម៉ែឪគាត់មិនចង់ឃើញកូនអញ្ចឹង បានគាត់គំរាមយើងថា កុំថាឡើយកូនមួយកូនម៉ាចំហៀងក៏អត់អនុគ្រោះឲ្យយើងដែរគាត់និយាយអញ្ចឹង ចា៎!ខ្ញុំក៏ប្តេជ្ញាចិត្តថាម៉ែអើយ ម៉ែឯងមិនបាច់

ភ័យដឹងខ្លួនខ្ញុំទេ ថាបើខ្ញុំទៅហួសហើយមិនវិលវិញទេម៉ែ មិនបាច់ភ័យទេម៉ែ ប្រសិនណាម៉ែឯងឃើញខ្ញុំផ្ញើរសំបុត្រទៅឲ្យម៉ែឯង ម៉ែឯងធ្វើបុណ្យឲ្យខ្ញុំផងច្បាស់ជាខ្ញុំស្លាប់ហើយខ្ញុំនិយាយប្រាប់គាត់អញ្ចឹងអូន ។

សេងគា ៖ បាទ!

ខុន ៖ ចាំ!យើងកុំឲ្យគាត់លំបាកយើងនោះ ហើយខ្ញុំក៏ប្ដេជ្ញាចិត្តអញ្ចឹង ។

សេងគា ៖ មីងស្ម័គ្រចិត្តទៅ គេក៏ព្រមឲ្យម៉ោទៅ?

ខុន ៖ ចាំ!

សេងគា ៖ ព្រមម៉ោហ្នឹងមុនដំបូងធ្វើជា?

ខុន ៖ ធ្វើជាកងទ័ពស្រុកហ្នឹង ។

សេងគា ៖ ស្រុកព្រៃកប្បាសហ្នឹងមីង?

ខុន ៖ ចាំ!

សេងគា ៖ បន្ទាប់មកទៀត?

ខុន ៖ បន្ទាប់មកទៀតម៉ោនៅក្នុងកងស្រុកហ្នឹងបានយូរដែល បានគេរើសនារីៗហ្នឹងឲ្យថាឲ្យឡើងម៉ោស្រែអំបិល ។

សេងគា ៖ ប៉ុន្តែនៅហ្នឹងបានប្រហែលប៉ុន្មានឆ្នាំដែរ?

ខុន ៖ នៅអត់បានយូរទេ នៅបានប្រហែលជាមើល៍ខែ៣ឬអីទេបានខ្ញុំឡើងនៅពីខែ២ម៉ោស្រែអំបិលភាគហ្នឹង បានគេរើសនារីៗហ្នឹង ឲ្យថាឲ្យឡើង ម៉ោស្រែអំបិល ។

សេងគា ៖ បាទ!ប៉ុន្តែម៉ោនៅហ្នឹងបានប្រហែលប៉ុន្មានឆ្នាំដែរ?

ខុន ៖ នៅអត់បានយូរទេអូន នៅបានប្រហែលជាខែ៣ឬអីទេ អញ្ចឹងបានខ្ញុំនៅខែ២រហូតដល់នេះខ្ញុំបាននៅ៥ខែទ័ពស្រុក ។

សេងគា ៖ នៅពីខែ៣រហូតដល់ខែ៧?

ខុន ៖ ចាំ!បានឡើងម៉ោស្រែអំបិលភាគហ្នឹង ។

សេងគា ៖ កាលហ្នឹងនៅទ័ពហ្នឹងគេឲ្យហាត់អីខ្លះមីង?

ខុន ៖ ហាត់យោធា ដូចយើងហាត់ទាហានយើងរាល់ថ្ងៃនេះអញ្ចឹង ។

សេងគា ៖ ហាត់បាញ់កាំភ្លើងហាត់អីហ្នឹង?

ខុន ៖ ចាំ!ហាត់បាញ់កាំភ្លើង ហាត់លូនហាត់ក្រាប ។

សេងគា ៖ ពីណាគេអ្នកប្រធានកន្លែងកងទ័ពហ្នឹង?

ខុន ៖ ប្រធានឥឡូវគាត់ស្លាប់បាត់ហើយ ។

សេងគា ៖ ឈ្មោះអីគេប្រធានកងទ័ព?

ខុន ៖ ប្រធានកងទ័ពហ្នឹងឈ្មោះ បងសន បងឡាង១ស្រុករបងឡាងប្រធាន១នារីហ្នឹង ។

សេងគា ៖ ឈ្មោះ សន?

ខុន ៖ ចាំ!បងសន ដូចមិនទាន់ស្លាប់ទេ ។

សេងគា ៖ នៅរស់ទេឥឡូវ?

ខុន ៖ ចាំ!កាលហ្នឹងដូចនៅរស់ទេ ។

សេងគា ៖ គាត់នៅណាឥឡូវហ្នឹង?

ខុន ៖ គាត់នៅស្រុកកន្ត្អប ប៉ុនឥឡូវអត់ដឹងគាត់នៅណាទេ គាត់ម៉ោស្រែអំបិលនេះដែរ ដល់នេះគេថាគាត់ក្បត់អញ្ចឹង គេចាប់គាត់ចងទៅលិច កើត ដើង ត្បូង តាសនហ្នឹង ។

សេងគា ៖ មិត្ត សន ហ្នឹងគាត់ប្រធានធំជាងគេមីង?

ខុន ៖ ចាំ!គាត់ធំកាលនៅកងស្រុក ។

សេងគា ៖ ចុះមិត្តអីមួយទៀត?

ខុន ៖ បងឡាងហ្នឹងគាត់អនុទេ ហើយដល់ក៏បែកគ្នារហូតទៅបងឡានហ្នឹង បងសន គាត់នៅ ជាប់ចាំនៅជាប់ជាមួយគាត់រហូតដល់គាត់ម៉ោនៅស្រែហ្នឹងជាមួយខ្ញុំក្នុងខេត្តកំពត ហ្នឹងបានប្រហែលមួយខែគេបំបែកគាត់ពីខ្ញុំហើយ ខ្ញុំម៉ោនៅណាទេនៅលកណាទេ ប៉ុនដល់នេះគេថាគាត់នឹងក្បត់ ដល់នេះគេចាប់សនហ្នឹងចងទៅលិចទៅកើតទៅ ដូចថាគាត់ហ្នឹងឆ្អតខួរក្បាលអស់ណាស់ ចាំ!ត្រឡប់ត្រលិនអស់ទៅ ។

សេងគា ៖ គេចាប់ពីណា គេចាប់កន្លែងកងពលហ្នឹងឬកន្លែងស្រែអំបិល?

ខុន ៖ ពីកន្លែងស្រែអំបិលហ្នឹងម៉ង ។

សេងគា ៖ អ្ហូ!គេដឹងឬយ៉ាំងម៉េច?

ខុន ៖ គេថាគាត់ក្បត់ខ្សែរយៈតា តាស្អីទេ ។

សេងគា ៖ តាម៉ុក?

ខុន ៖ តាម៉ុកស្អី ប្អូនតាម៉ុក តាចុង១ហ្នឹងប្អូនតាម៉ុក តាហម តាចុងហ្នឹងប្អូនតាម៉ុក ។

សេងគា ៖ អ្ហូ!តាចុង?

ខុន ៖ ចាំ!ហ្នឹងខ្សែបទគេណាណើនោះពីតាហមម៉ោនោះ ។

សេងគា ៖ តាចុងហ្នឹងចោទ?

ខុន ៖ តាចុងអី ពួកភាគយើងនេះ ពួកអ្នកនៅស្រែអំបិលហ្នឹងគេចោទថាយើងហ្នឹងក្បត់ ហ្នឹងហើយដល់ហើយគេចាប់គាត់ទៅលិចទៅដើងត្បូងឡើងឆ្គតវិលអស់ហើយ ។

សេងគា ៖ បាទៗមីងអញ្ចឹងមានន័យថា កាលដែលមីងនៅហ្នឹងទ័ពទាំងអស់មានប៉ុន្មាននាក់នៅក្នុងកន្លែងស្រុកមីងនៅ?

ខុន ៖ ទ័ពស្រុកច្រើនដែរ ។

សេងគា ៖ ប្រហែលជាប៉ុន្មានរយនាក់?

ខុន ៖ ប្រហែលម៉ាកងស្រុកៗហ្នឹង កាលហ្នឹងវាមានអន្តភាពច្រើនដែល កាលហ្នឹងខ្ញុំវានៅតូចដែរដូចថាវាមិនទាន់បានចេះគិតវែងឆ្ងាយអីណាស់ មិនសូវដឹងអីប៉ុន្មានទេ ដឹងថាក្នុងម៉ាកង ។

សេងគា ៖ ប៉ុនមីងឃើញច្រើន?

ខុន ៖ ចា៎!ដឹងថាក្នុងម៉ាកងហាគេអញ្ចឹងទៅ ម៉ាក្រុមៗគេ១២នាក់ពេញៗម៉ង ។

សេងគា ៖ មីងកងអីគេ?

ខុន ៖ ខ្ញុំអត់ដឹងថាកងអីទេ ដឹងថាកងលេខប៉ុន្មានអីប៉ុន្មានទេ គ្រាន់តែដឹងថា ។

សេងគា ៖ មីងអត់ចាំលេខចាំអីទេ?

ខុន ៖ ចា៎!អត់ចាំលេខទេ គ្រាន់តែដឹងថាស្រុក ប៉ុនគ្រាន់តែថាដូចនៅក្នុងក្រុមក្នុងអីគេអញ្ចឹង ទៅគេមិនចាត់ទុកយើងក្នុងក្រុមផងគេចាត់ទុកយើងនិរសាគេនោះ ឲ្យនៅនិរសាជាមួយគាត់ឲ្យដើរលិចដើរកើតទៅជាមួយគេហ្នឹងជាមួយ បុល នោះ ។

សេងគា ៖ ចុះមិត្តសន ហ្នឹងគាត់មនុស្សម៉េចដែរ?

ខុន ៖ សនហ្នឹង?

សេងគា ៖ បាទ!

ខុន ៖ សនហ្នឹងរូបរាងគាត់ដូចប្រុសអញ្ចឹង ខ្ពស់ រាងគាត់ប្រុសគាត់ពាក់ខោអាវតែប្រុសៗទេសនហ្នឹង អញ្ចឹងបានថាឥឡូវមិនដឹងថាគាត់ទៅណាយើងបែកយូរហើយ តាំងពី៧/៨ម៉ោរហូតម៉ោ តាំងពីម៉ោពីនេះម៉ោ ។

សេងគា ៖ មីងគិតថាប្រហែលគាត់នៅរស់?

ខុន ៖ ចា៎!ខ្ញុំថាប្រហែលគាត់នៅរស់ ។

សេងគា ៖ ចុះមិត្ត ឡាង?

ខុន ៖ ឡាងហ្នឹងខ្ញុំថាប្រហែលជានៅរស់ដែរមើលទៅ ។

សេងគា ៖ អញ្ចឹងទាល់តែពេលនៅហ្នឹងបានប្រហែលជា៥ខែ នៅកន្លែងស្រុកហើយគេបញ្ជូនម៉ោកន្លែងស្រែអំបិលវិញ?

ខុន ៖ ចា៎!គេបញ្ជូនម៉ោស្រែអំបិលទាំងអស់គ្នាវិញ ។

សេងគា ៖ កាលហ្នឹងជិះអីម៉ោ អ្នកណាអ្នកបញ្ជូនម៉ោ?

ខុន ៖ បញ្ជូនម៉ោ តាម៉ុក ។

សេងគា ៖ តាម៉ុក?

ខុន ៖ ចា៎!តាម៉ុកគាត់ជាអ្នកបញ្ជូនម៉ោ ។

សេងគា ៖ អញ្ចឹង ៥ខែ ពី៧៨ អញ្ចឹងមីងមិញម៉ោពីខែ៣ ឆ្នាំ៧៨ជិតចូល៥៧ឬនៅ នៅទេ?

ខុន ៖ ៧៨ហ្នឹងវា ។

សេងគា ៖ ចុង៧៨?

ខុន ៖ ចា៎!

សេងគា ៖ ទៅដល់ស្រែអំបិលចូល៧៩ឬនៅ?

ខុន ៖ អត់ទេនៅក្នុង៧៨ដែរ យើងប៉ុន្មានខែ ខ្ញុំនៅកងស្រុកបានប៉ុន្មានខែហ្នឹង មើលខ្ញុំនៅតាំងពី៧៥រហូតដល់៧៨នៅស្រែអំបិលអត់បាន៤ឆ្នាំផងហ្នឹង ប៉ុនគ្រាន់តែថាយើងរាប់ទៅវាអត់បានពេញ៤ឆ្នាំ ប៉ុនក្នុងរយៈហ្នឹងវាចូល៤ឆ្នាំហើយ ៧៥រហូតដល់៧៨វា៤ហើយណាស់ ប៉ុនវាខ្វះខែខ្វះថ្ងៃអីយើងមិនដឹងទេណា៎ ដំនាន់ហ្នឹងយើងរាប់តែអញ្ចឹងទៅមិនដឹងគិតខែគិតថ្ងៃអីទេ ។

សេងគា ៖ ឲ្យទៅស្រែអំបិល?

ខុន ៖ ទៅស្រែអំបិលភាគហ្នឹង ។

សេងគា ៖ ធ្វើអី អាហ្នឹងគេហៅថាម៉េចអាហ្នឹង?

ខុន ៖ គេហៅស្រែអំបិលភាគ យើងភាគតំបន់អញ្ចឹងវាខុសគ្នា ។

សេងគា ៖ ស្រែអំបិលភាគ?

ខុន ៖ ចា៎!

សេងគា ៖ នៅភូមិអីគេមីង?

ខុន ៖ នៅស្រែអំបិលហ្នឹងនៅភូមិស្រែយល់ ។

សេងគា ៖ ស្រែយល់?

ខុន ៖ ចា៎!ប៉ុនមិនដឹងនៅក្នុងឃុំអី ឃុំស្រែខ្លាវ ឬឃុំអី ។

សេងគា ៖ ចុះស្រុកអីគេ?

ខុន ៖ មិនដឹងស្រុកអីទេ ដឹងតែថានៅក្បែរកែបហ្នឹង ។

សេងគា ៖ នៅក្បែរកែប?

ខុន ៖ ចា៎!នៅក្បែរកែប ស្រែយល់កែបកោលហ្នឹងក្បែរគ្នាហ្នឹង ចេញពីកែបទៅដល់បន្ទិចដល់ស្រែយល់ហ្នឹងម៉ង បែបនៅក្នុងឃុំក្រាំងលាវហ្នឹងមិនដឹងទេ ខ្ញុំចាំមិនអស់ទេ ខ្ញុំមិនដែលដើរទៅក្នុងឃុំគេផង គ្រាន់តែដឹងថានៅក្នុងហ្នឹង ។

សេងគា ៖ ម៉េចបានតាម៉ុកឲ្យទៅហ្នឹង?

ខុន ៖ ពួកខ្ញុំហ្នឹងវាចូលក្នុងភាគហើយ ចូលក្នុងកូនចៅគាត់ហ្នឹង ។

សេងគា ៖ អ្ហ៎!អញ្ចឹងគាត់ឲ្យទៅនៅហ្នឹងម៉ង?

ខុន ៖ ចា៎!កូនចៅគាត់ស្រេចតែគាត់ចាត់តាំងឲ្យយើងទៅណាទេ មេៗគេដែរ ។

សេងគា ៖ ឲ្យតែចូលនៅក្នុងកងស្រុកជាកូនចៅគាត់ហើយ?

ខុន ៖ ចា៎!កាលនៅក្នុងកងស្រុកអត់ទេ យើងនៅក្នុងស្រុកយើងកូនចៅតាចុងនៅឡើយទេ ។

សេងគា ៖ ស្រុកប្រធានស្រុកវាតាចុង?

ខុន ៖ ចា៎!

សេងគា ៖ ប្អូនតាម៉ុក?

ខុន ៖ ចា៎!កាលយើងនៅក្នុងស្រុកវាមានប្រធានផ្សេងហើយកាលហ្នឹង ។

សេងគា ៖ ប្រធានកងស្រុក?

ខុន ៖ សន ហ្នឹងហើយ បន្ទាប់ពីចុងហ្នឹងគណៈស្រុកហើយ ។

សេងគា ៖ ប្រធានទ័ព?

ខុន ៖ សន គេគណៈស្រុកទេដែលដឹកនាំយើងដែលថាមានកងស្រុកកងអីហ្នឹងណាស់ជាមួយចុងហ្នឹង?

សេងគា ៖ បាទ!ទាល់តែគណៈស្រុក ចុង?

ខុន ៖ ចា៎!ទាល់គណៈតំបន់អ៊ឹអត់ស្គាល់ទេ ។

សេងគា ៖ ទាល់តែពេលនៅហ្នឹងរួចហើយ បានគេឲ្យឡើងម៉ោភូមិភាគវិញ?

ខុន ៖ ដូចថាយើងនៅស្រុកអញ្ចឹង វាច្រើនពេកអញ្ចឹងទៅគេលែងចង់ឲ្យមានកងស្រុកហើយវាអត់មានគេបញ្ជូន ។

សេងគា ៖ អញ្ចឹងតា ចុង បញ្ជូនឲ្យម៉ោស្រុកវិញ?

ខុន ៖ ចា៎! គេឲ្យឡើងម៉ោស្រែអំបិលភាគនេះម៉ោ ។

សេងគា ៖ ម៉ោស្រែអំបិលភាគជាកូនចៅតាម៉ុកវិញ?

ខុន ៖ ចា៎! ជាកូនចៅតាម៉ុកវិញហើយ ប៉ុនគ្រាន់តែថា ។

សេងគា ៖ អញ្ចឹងគា ចុងអ្នកបញ្ជូនទេ?

ខុន ៖ តាម៉ុកទៅសុំអីមិនដឹងទេកាលហ្នឹង យើងវាមិនដឹងតាមរយៈហ្នឹងយើងនិយាយញ៉ឹងម៉ង ទៅអាហ្នឹងទៅតាមរយៈហ្នឹង ។

សេងគា ៖ បាទ! ទាល់តែទៅនៅស្រែអំបិលហ្នឹងជាកូនចៅតាម៉ុកវិញ?

ខុន ៖ គ្រាន់តែដឹងថាភាគហ្នឹងយើងភូមិភាគហ្នឹងយើងកូនចៅតាម៉ុកហើយ ប៉ុនអ្នកក្តាប់នៅស្រែអំបិលហ្នឹងមិនមែនតាម៉ុកហ្នឹងអ្នកក្តាប់ទេ មានផ្សេងទៀតអ្នកក្តាប់យើង ។

សេងគា ៖ អ្នកណាគេ ប្រធាននៅហ្នឹង?

ខុន ៖ ប្រធានខ្ញុំហ្នឹងឈ្មោះបង ពូសៀន ហ្នឹងប្រធានវរៈគេហើយហ្នឹង តាមរយៈគេ ។

សេងគា ៖ ប្រធាននៅ?

ខុន ៖ ស្រែអំបិលភាគហ្នឹងឈ្មោះ ពូសៀន អាហ្នឹងប្រធានវរៈសេនាតូចទៀត ។

សេងគា ៖ ប្រធាននៅស្រែអំបិលភាគហ្នឹងឈ្មោះ មិត្ត សៀន?

ខុន ៖ ចា៎!

សេងគា ៖ មិត្តៀន ហ្នឹងគាត់ជានរណាគេ?

ខុន ៖ ពុ សៀនហ្នឹង?

សេងគា ៖ បាទ!

ខុន ៖ ពូ សៀនហ្នឹងគាត់ឥឡូវមិនដឹងនៅរស់មិនដឹងអីដែរ ប៉ុនគាត់ឡើងម៉ោក្នុងបាត់ដំបងហ្នឹង ដែរ ប៉ុន្តែមិនដឹងនៅកន្លែងណាទេឥឡូវ ។

សេងគា ៖ អញ្ចឹងមិត្ត សៀន ហ្នឹងគាត់ប្រធានភូមិភាគ?

ខុន ៖ គាត់ប្រធាននារីក្នុងស្រែអំបិលហ្នឹងម៉ង ។

សេងគា ៖ ស្រីឬប្រុស?

ខុន ៖ ស្រី ប្រធានមា៉អគ្គភាពៗហ្នឹង ។

សេងគា ៖ ប៉ុន្តែអ្នកដែលគ្រប់គ្រងខេត្តទាំងមូលហ្នឹងនរណាគេ?

ខុន ៖ ខេត្ត?

សេងគា ៖ នៅក្នុងស្រុកស្រែអំបិលហ្នឹង?

ខុន ៖ នៅក្នុងស្រុកស្រែអំបិលដែលធំជាងគេបង្អស់ កាលហ្នឹងមិនដឹងបងអីទេ បងធំ មិនដឹងបងអីទេ ។

សេងគា ៖ បាទ!អញ្ចឹងនៅពេលហ្នឹង ម៉េចបានមីងដឹងនៅក្នុងភាគគឺជាកូនចៅតាម៉ុកវិញ?

ខុន ៖ ដឹង ។

សេងគា ៖ ម៉េចបានដឹង?

ខុន ៖ មិនដឹងអីបើក្នុងភាគវាត្រូវកូនចៅតាម៉ុកអញ្ចឹងម៉ង តាម៉ុកថាឲ្យទៅណាទៅហ្នឹង ។

សេងគា ៖ នៅស្រែអំបិលហ្នឹងមានគ្នាវេចើនទេមីង?

ខុន ៖ ចា៎!មានគ្នាច្រើនណាស់ រាប់ពាន់នាក់ ។

សេងគា ៖ នៅកន្លែងតំបន់របស់មីងហ្នឹងមានគ្នារាប់ពាន់នាក់?

ខុន ៖ ចា៎!រាប់ពាន់នាក់ គ្រាន់តែក្នុងពួកខ្ញុំដែលគាត់កាន់កាប់ហ្នឹងមានស្រែយល់ ស្រែកោល អញ្ចឹងបានថាវាធំណាស់វាច្រើនណាស់ ។

សេងគា ៖ ស្រែយល់?

ខុន ៖ ស្រែយល់ ហើយព្រៃឃ្លាំង ។

សេងគា ៖ ព្រៃឃ្លាំង?

ខុន ៖ ចា៎!អាហ្នឹងសុទ្ធតែអង្គភាពតូចៗហើយ ។

សេងគា ៖ បាទ!

ខុន ៖ កោះកុល ហើយនឹងអីមួយទៀតទេ ភ្នំពូន ។

សេងគា ៖ ភ្នំពូន?

ខុន ៖ ចា៎!ច្រើនណាស់អូន មីងស្គាល់អត់អស់ទេភ្លេចកន្លែងអស់ហើយដូចយូរទៅ ។

សេងគា ៖ អាហ្នឹងម៉ាតំបន់កន្លែង?

ខុន ៖ ចា៎!កន្លែងគាត់កាន់កាប់ទៅ ។

សេងគា ៖ មីងនៅជាមួយពួកគាត់ហ្នឹង?

ខុន ៖ ចា៎!

សេងគា ៖ ហើយគាត់ជាមនុស្សម៉េចដែល?

ខុន ៖ គាត់ខ្មៅ ទាបដែរ ។

សេងគា ៖ គាត់កាចទេ?

ខុន ៖ គាត់អត់សូវកាចប៉ុន្មានទេ ប៉ុនចំពោះខ្ញុំ ខ្ញុំថាមិនកាច ក្រែងកូនចៅគេ គេថាកាច ប៉ុន ខ្ញុំរស់នៅជាមួយគាត់ គាត់អត់មានកាចទេ ។

សេងគា ៖ បាទ!មីងរស់នៅជាមួយគាត់ធ្វើអីគេ?

ខុន ៖ ខ្ញុំនៅកងការពារ ដូចខ្ញុំនិយាយម៉េចអញ្ចឹង ។

សេងគា ៖ អ្ហូ!កងការពារ?

ខុន ៖ ចា៎!

សេងគា ៖ ជួយការពារគាត់?

ខុន ៖ ជួយការពារទាំងអស់ អត់មានការពារតែគាត់ទេ ការពារកន្លែងស្រែអំបិលក្នុងអន្តភាព យើងម៉ង ។

សេងគា ៖ មីងកាន់កាំភ្លើងការពារដែរ?

ខុន ៖ ចា៎!កាន់កាំភ្លើងការពារតាមមាត់សមុទ្រម៉ង ។

សេងគា ៖ តាមមាត់សមុទ្រ?

ខុន ៖ ចា៎!

សេងគា ៖ ប៉ុន្តែការហូបចុកអីយ៉ាងម៉េចដែរ?

ខុន ៖ អត់អីទេ ការហូបចុកអីវាជាធម្មតាដែរ វាជួបប្រទះនឹងអត់ឃ្លានច្រើនដែរ ប៉ុនគ្រាន់តែថាដូចខ្ញុំការពារអញ្ចឹងទៅ ដូចថាហូប បើនិយាយពីហូបបបរដូចតែគ្នាអញ្ចឹង ប៉ុនគ្រាន់តែថាពេលណាដែលខ្ញុំហូបក្នុងអន្តភាព ខ្ញុំហូបតិចៗទៅព្រោះខ្ញុំដើរតាមមាត់សមុទ្រអញ្ចឹងមានប្រជាជនអី គាត់នៅធ្វើនេសាទសមុទ្រអីអញ្ចឹង តំបន់យើងកំពតហ្នឹង គេឃើញយើងអញ្ចឹងគេបេះទុកបង្គារ មីកអីអញ្ចឹងឲ្យយើងហូបទៅណា ។

សេងគា ៖ បាទ!

ខុន ៖ ចា៎!អញ្ចឹងបានថាខ្ញុំវា ការលំបាកមិន ។

សេងគា ៖ អញ្ចឹងបានន័យថាមិត្ត សៀន ចូលចិត្តអ៊ីដែរ?

ខុន ៖ ចា៎!គាត់ចូលចិត្តខ្ញុំ ។

សេងគា ៖ ចុះអនុមិត្ត សៀនហ្នឹងគាត់ឈ្មោះអី?

ខុន ៖ អនុគាត់ហ្នឹង ដូចឈ្មោះ បងរីម ។

សេងគា ៖ មិត្តនារីរីម?

ខុន ៖ ចា៎!

សេង៉គា ៖ បាទ!ហើយបន្ទាប់មកទៀតមានអ្នកណាគេទៀត ។

ខុន ៖ ៣នាក់ប៉ុនមិនដឹងអ្នកណាម្នាក់ទៀតទេ ដល់នេះរូបម៉ោដូចបង៉រីមហ្នឹងមួយ ដូចបង៉ទូន ហ្នឹងមួយទៀត នៅកង៉ហាគេហ្នឹងពូទូន ។

សេង៉គា ៖ ចុះរីមនេះនៅកង៉រយ?

ខុន ៖ ចា៎!នៅកង៉រយ ។

សេង៉គា ៖ កង៉រយគាត់ក្ដាប់ទាំងអស់?

ខុន ៖ ចា៎ពូ សៀន បានគាត់ក្ដាប់ទាំងអស់ បន្ទាប់មកបានបង៉ ទូន ។

សេង៉គា ៖ រីម នេះនៅកង៉រយ?

ខុន ៖ ចា៎!រីមហ្នឹងចុះពី ពូសៀមម៉ោមិញដូចថាអនុគេអញ្ជឹង ប្រធាន អនុប្រធាន ។

សេង៉គា ៖ កង៉រយមានគ្នាប៉ុន្មាននាក់?

ខុន ៖ កង៉រយវាម៉ាក្រុម ម៉ាកង៉តូចគេហ្នឹងវាមាន៣០នាក់ ក្រុមវាមាន១០នាក់ ។

សេង៉គា ៖ ចុះម៉ាកង៉ហាមានប៉ុន្មាន?

ខុន ៖ ម៉ាកង៉ហា ម៉ាក្រុមមាន១០នាក់ ម៉ាកង៉ហាមាន៣០នាក់ហ្នឹងឯង ។

សេង៉គា ៖ ម៉ាកង៉ហាមាន៣០នាក់?

ខុន ៖ ចា៎!ចុះក្រុមមាន១០នាក់ ម៉ាកង៉ហាមាន៣ក្រុម ។

សេង៉គា ៖ ចុះប៉ុន្មានកង៉ហាបានស្មើកង៉រយ ប៉ុន្មានក្រុម?

ខុន ៖ អាច៣ក្រុមម៉ាកង៉ហា មិនមែនម៉ាកង៉ហា៣ក្រុមទេ ម៉ាកង៉រយ អាច៦ក្រុមហើយ មើលខ្ញុំនឹកសិន ។

សេង៉គា ៖ និយាយពី ៣កង៉ហាបានស្មើម៉ាកង៉រយ?

ខុន ៖ ចា៎!ត្រូវហើយអាហ្នឹងអញ្ជឹងហើយ ។

សេង៉គា ៖ ហើយម៉េចឈ្មោះមិត្តអីមួយទៀត មិត្តទូន?

ខុន ៖ មិត្ត ទូន ។

សេង៉គា ៖ អនុទី៣?

ខុន ៖ អត់ទេ!មិនមែន បង៉ទូនទេ បង៉ទូតទេ ។

សេង៉គា ៖ កង៉ហាមានតាមក្រុម មានប៉ុន្មានក្រុម?

ខុន ៖ ម៉ាកង៉ហាគេហ្នឹងវាអាចមាន៣ក្រុម អាចទៅ៦ក្រុម ។

សេង៉គា ៖ បើគ្នាមួយក្រុមមានគ្នា ១០នាក់?

ខុន ៖ ១០នាក់ ។

សេងគា ៖ គ្នា១០នាក់ទៅ១២នាក់មីង?

ខុន ៖ ចាំ!១០នាក់ទៅ១២នាក់ វាត្រូវហើយអាហ្នឹងម៉ាក្រុមៗគេ យើងអត់បានទៅក៏១០អានេះ១២នាក់ទៅ ។

សេងគា ៖ អញ្ចឹងមិត្តទាំង៣នាក់ហ្នឹងបូកចន្លោមគ្នាប្រហែលជារាប់ពាន់នាក់មីង?

ខុន ៖ ចាំ!នៅក្នុងម៉ាកងដែលគាត់ក្តាប់ហ្នឹងជាប់តែ ម៉ាអង្គភាពគាត់ជាប់តែ១ពាន់នាក់អី ដែលហ្នឹងប្រធានក្តាប់ហ្នឹងធំណាស់ ។

សេងគា ៖ អញ្ចឹង!មានន័យថាជិតដល់កងវរយហើយ?

ខុន ៖ ចាំ!ដូចថាវាច្រើនវាធំដឹយកចិត្តទុកដាក់ របស់អ្នកណាអ្នកណីទេ ។

សេងគា ៖ ប្រហែលជា១ពាន់នាក់ជាងមីង?

ខុន ៖ ចាំ!វាច្រើន ដល់ហើយយើងមិនអាចដឹងអស់ទេ ឥឡូវវាយូរឆ្នាំលែងយកចិត្តទុកដាក់ហើយ ។

សេងគា ៖ បាទ!

ខុន ៖ ចាំ!ដូច បងអ៊ីន ប្រពន្ធតាជានអីហ្នឹងប៉ុនគាត់អាចចាំហើយ អាហ្នឹងគាត់មេដែល ។

សេងគា ៖ អញ្ចឹង?

ខុន ៖ ចាំ! បងអ៊ីន ប្រពន្ធតាជាន លោកជានយើងហ្នឹង ។

សេងគា ៖ បាទ!អញ្ចឹងមីងនៅកំពត នៅក្នុងកងហ្នឹងបានប្រហែលជាប៉ុន្មាន ៤ឆ្នាំ?

ខុន ៖ បាន៤ឆ្នាំ តាំងពី៧៤រហូតដល់៧៨ ខ្ញុំនៅស្រែអំបិលហ្នឹងយូរណាស់ នៅការពារហ្នឹងយូរណាស់ ប៉ុនអត់មានដែលដើរទៅណាក្រៅពីនៅតែក្នុងវង្វង់ស្រែអំបិល ហើយនឹងមាត់សមុទ្រហ្នឹងទេ អត់ដែលដើរទៅណាទេក្នុងម៉ាវយៈហ្នឹង នៅតែក្នុស្រែអំបិល ដល់ចេញពីស្រែអំបិលណាអូន ហ្នឹងចប់ពីស្រែអំបិល ។

សេងគា ៖ ជាកងការពារសន្តិសុខ?

ខុន ៖ អាហ្នឹងអាចថាសន្តិសុខក៏ថាបាន កងការពារក្នុងស្រែអំបិលពីមុនគេមិនថាសន្តិសុខដូចយើងឥឡូវទេ យើងពីមុនគេហៅកងការពារអញ្ចឹង យើងបច្ចុប្បន្នយើងថាសន្តិសុខក៏ត្រូវដែលហ្នឹង ។

សេងគា ៖ ការពារតំបន់?

ខុន ៖ ចាំ!ការពារទឹកន្លែងដែលយើងរស់នៅក្នុងស្រែអំបិលហ្នឹង ។

សេងគា ៖ អញ្ចឹងនៅពេលដែលមីងនៅហ្នឹង មីងមានជួបមានបាញ់គ្នានៅក្នុងហ្នឹងប្អត់?

ខុន ៖ ខ្ញុំនៅស្រែអំបិលហ្នឹងអត់មានបាញ់គ្នាអីទេ ។

សេងគា ៖ កាន់តែកាំភ្លើងទេមីង?

ខុន ៖ ចា៎!គ្រាន់កាន់តែកាំភ្លើងទេ អត់ដែលបានបាញ់អីទេ ។

សេងគា ៖ ហើយមានគេធ្វើបាបអីផ្សេងៗទៀតទេ?

ខុន ៖ អត់ទេខ្ញុំអត់មានទេ ។

សេងគា ៖ គេផ្សេងៗទៀតអត់ដែរ?

ខុន ៖ គេក៏អត់ដែរ ។

សេងគា ៖ អ៊ូ!នៅក្នុងហ្នឹងស្រួលរហូត?

ខុន ៖ ចា៎!សុខស្រួលទាំងអស់ ។

សេងគា ៖ ប្រជាជនផ្សេងៗគេឲ្យធ្វើអីខ្លះទៅ?

ខុន ៖ អ្នក ប្រជាជនផ្សេងៗទៀតគ្នាអត់មានធ្វើអីសោះ បុកតែគុបធ្វើស្រែអំបិលហ្នឹងដូចតែគ្នា ។

សេងគា ៖ ចុះមីងមានមិត្តភក្តិជិតនិតអីនៅជាមួយគ្នាជាប់ស្រឡាញ់គ្នាអីអញ្ចឹង?

ខុន ៖ មាន ។

សេងគា ៖ ឈ្មោះអីខ្លះមីង?

ខុន ៖ ចា៎!ខ្ញុំដូចថាស្រឡាញ់ជិតស្និតឈ្មោះ រ៉េត អាហ្នឹងដូចថាដូចរាប់ដូចបងប្អូនយើង មានកាលហ្នឹងដូចថា«យើងនៅផ្ទះម្តាយទីទៃ នៅព្រៃម្តាយតែមួយ» ចេះតែរាប់អានគ្នា ទៅ ។

សេងគា ៖ បាទ!ឈ្មោះមិត្តនារី រ៉េត?

ខុន ៖ ឈ្មោះ រ៉េត ហ្នឹងក៏ខ្ញុំនៅរាប់អានដែលរាល់ថ្ងៃ ។

សេងគា ៖ គាត់ធ្វើអីគេ?

ខុន ៖ កាលហ្នឹងអ្នកនៅស្រែអំបិលហ្នឹង អ្នកនៅកងការពារដែរ ។

សេងគា ៖ អ្នកនៅកងការពារជាមួយមីងដែរ?

ខុន ៖ ចា៎!ជាមួយខ្ញុំដែរ ។

សេងគា ៖ អញ្ចឹងមីងស្រឡាញ់ម្នាក់ហ្នឹងជាងគេ?

ខុន ៖ ចា៎!ស្រឡាញ់គ្នាណាស់ ទាល់រាល់ថ្ងៃហ្នឹងក៏នៅរាប់អានគ្នាដែរ ។

សេងគា ៖ អញ្ចឹងគាត់នៅជិតនេះដែរ?

ខុន :	គាត់ឥឡូវនេះ?

សេងគា :	បាទ!

ខុន :	គាត់វិលទៅនៅស្រុកបាត់ហើយ ។

សេងគា :	ស្រុកណាមីង?

ខុន :	នៅអាដែងណែ៎ក្បែរភ្នំមីមៀលនេះ នៅឃុំពោករុន អុស៎!ឃុំស្រណោះ ពោករុន អីក៏ស្រណោះអញ្ចឹងហើយ ប៉ុនមិនដឹងឃុំអីទេ តែដឹងតែ២ហ្នឹង ពោករុន ហើយស្រណោះហ្នឹងដឹងតែនៅក្បែរភ្នំមីមៀលហ្នឹងម៉ង ។

សេងគា :	ពីមុននៅនេះទេ?

ខុន :	ចា៎!កាលមុននៅនេះដែរ ដឹប្ដីវាឈឺទៅមើលមិនជាទៅ ដឹទៅមើលតាមកកុងម៉ាទៅ ហើយអត់ម៉ោវិញនៅស្រុកហ្នឹងហូតទៅ ។

សេងគា :	ភ្នំមីងមៀលនៅកន្លែងណាមីង នៅខេត្តតាកែវ?

ខុន :	ខេត្តនេះ ខេត្តកំពតហើយ ភ្នំមីមៀលហ្នឹងឃុំពោករុននៅកំពតហើយ ប៉ុនតែដឹងថាភូមិពោករុន ឬភូមិកំណប់តែប៉ុនហ្នឹង ចា៎!អាពីរហ្នឹងវាបញ្ចូសគ្នាមិនដឹងមួយណា ។

សេងគា :	មីងរាប់អានជិតដិតជាងគេ?

ខុន :	ចា៎!ជិតដិតជាងគេ ។

សេងគា :	រត់ម៉ោពីស្រែអំបិលជាមួយគ្នាដែរ?

ខុន :	ចា៎!រត់ពីណែ៎ ។

សេងគា :	ម៉េចបានរត់ពីស្រែអំបិលម៉ោមីង?

ខុន :	ពីស្រែអំបិលហ្នឹងម៉ោអត់មានរត់ទេ ឡើងម៉ោពីបាត់ដំបងហ្នឹងម៉ង ។

សេងគា :	អ្ហូ!ម៉េចបានឡើងម៉ោ?

ខុន :	តាម៉ុក ហៅម៉ោទៀត ។

សេងគា :	អ្ហូ!តាម៉ុកហៅឡើងម៉ោផ្ទាល់?

ខុន :	ចា៎!នៅក្នុងអគ្គភាពតាម៉ុក តាម៉ុកទៅហៅម៉ោទៀត ទៅហៅម៉ោស្រែអំបិលហ្នឹងទៀត ម៉ោបាត់ដំបងហ្នឹងទៀត ។

សេងគា :	នៅកន្លែងណា?

ខុន :	ចុះខ្ញុំប្រាប់ថានៅនឹងភូមិពាក់ស្បែកមិញ មុនដំបូងឈប់ចាំខ្ញុំនិយាយ មុនដំបូងគាត់ម៉ោដល់គាត់មិនទាន់ចាត់តាំងយើងឲ្យទៅនេះទេ គាត់ចាត់តាំងពួកខ្ញុំនឹងឲ្យនៅ ។

សេងគា ៖ អញ្ចឹង៧៨ហើយ ៧៨ឬ៧៩មីង?

ខុន ៖ ចាំ!៧៩ហ្នឹងហើយ ។

សេងគា ៖ ៧៩?

ខុន ៖ ចាំ!

សេងគា ៖ អញ្ចឹង៧៨មីងនៅហ្នឹងរហូតដល់ចុង៧៨ ដល់ដើម៧៩បានឡើងមកបាត់ដំបងវិញ?

ខុន ៖ ចាំ!បានឡើងម៉ោបាត់ដំបងហ្នឹងម៉ង ខ្ញុំនៅស្រែអំបិលរហូតហើយបានខ្ញុំឡើងមៅបាត់ដំបងហ្នឹង ។

សេងគា ៖ គាម៉ុកឲ្យនាំពីស្រែអំបិល?

ខុន ៖ ឲ្យឡើងម៉ោពីស្រែអំបិលហ្នឹងម៉ោ ម៉ោនៅបាត់ដំបងហ្នឹងហើយបានគាត់បែងចែកកូនចៅទាំងអស់ហ្នឹងទៅតាមសហករណ៍ទាំងអស់ហ្នឹង ខ្លះក៏នៅក្នុងក្រុងបាត់ដំបងហ្នឹងទៅ ខ្លះក៏ម៉ោតាមសហករណ៍គ្រប់សហករណ៍ទាំងអស់នេះម៉ោ ។

សេងគា ៖ ម៉ោនៅឃុំអីទេ?

ខុន ៖ ម៉ោនៅបាត់ដំបងហ្នឹង?

សេងគា ៖ បាទ!

ខុន ៖ ខ្ញុំម៉ោនៅភូមិពាក់ស្បែក ។

សេងគា ៖ ភូមិពាក់ស្បែក?

ខុន ៖ ចាំ!

សេងគា ៖ នៅម្តុំណាភូមិពាក់ស្បែក?

ខុន ៖ នៅខាងនេះស្ទឹង ចាំ!នៅឃុំបឹងព្រៃនោះ ចេញពីស្ទឹងទៅត្រង់ជើង ។

សេងគា ៖ ឃុំបឹងព្រៃ?

ខុន ៖ ឃុំបឹងព្រៃ ។

សេងគា ៖ ស្រុក?

ខុន ៖ មិនដឹងស្រុកអីគេទេ ខ្ញុំមិនស្គាល់ទេ ។

សេងគា ៖ ស្រុកបាណន់ ស្ទឹងស្រុកបាណន់?

ខុន ៖ អេស!មិនបាណន់ទេ ។

សេងគា ៖ ស្ទឹងបាណន់ហើយ?

ខុន ៖ ស្ទឹងបាណន់?

សេងគា ៖ បាទ!

ខុន ៖ ព្រោះអាដែងណែ៎ស្ទឹងហ្នឹងហើយពាក់ស្បែកវានៅជាប់គ្នា ខ្ញុំអត់ដឹងស្រុកអីខ្ញុំដឹងតែប៉ុនហ្នឹង ។

សេងគា ៖ តែឥឡូវស្ទឹងហ្នឹងនៅក្នុងស្រុកបាណន់ដែរ?

ខុន ៖ ស្រេចតែអូនឯងដឹង ខ្ញុំអត់ដឹងទេ ។

សេងគា ៖ អញ្ចឹងខ្ញុំអត់ទាន់ដាក់ទេ?

ខុន ៖ ចា៎!ព្រោះយើងអត់ដឹងថាអាហ្នឹងស្រុកអីអញ្ចឹង យើងពិបាកប្រាប់ដែរ ។

សេងគា ៖ មានតែស្រុកបាណន់?

ខុន ៖ ចា៎!ត្រូវហើយ ចេញពីស្ទឹង ពាក់ស្បែកហ្នឹងម៉ង ។

សេងគា ៖ កាលម៉ោជាមួយតាម៉ុកហ្នឹងមានគ្នាប៉ុន្មាននាក់?

ខុន ៖ ច្រើន ។

សេងគា ៖ ម៉ោទាំងកងទាំងអស់ ទាំងមិត្តសៀន ហ្នឹងម៉ង?

ខុន ៖ ចា៎!ម៉ោទាំងកងហ្នឹងម៉ង ។

សេងគា ៖ ជិះអីម៉ោកាលហ្នឹងម៉ោ?

ខុន ៖ ជិះរទេះភ្លើង ។

សេងគា ៖ ជិះរទេះភ្លើង អ៊ូ!មានរទេះភ្លើងជិះម៉ោ?

ខុន ៖ មាន ។

សេងគា ៖ បាទ!ជិះកាត់ពីណាទៅណា?

ខុន ៖ ជិះពី ខ្ញុំឡើងរទេះភ្លើងពីរនាក់អើ យើងកំពតហ្នឹងម៉ោ ម៉ោង១១ថ្ងៃត្រង់ម៉ោដល់បាត់ដំបងយើងម៉ោង១១យប់ ជិះរទេះភ្លើងយើង ។

សេងគា ៖ រទេះភ្លើង ពីរនាក់ពីណា?

ខុន ៖ ពីរនាក់ អើ មកចុះនៅវ៉ាយើងបាត់ដំបង ។

សេងគា ៖ ចុះបង អើ ហ្នឹងអ្នកកំពត?

ខុន ៖ ចា៎!អ្នកអើ អ្នកកំពត ។

សេងគា ៖ កំពតម៉ោរហូតដល់បាត់ដំបងហ្នឹង?

ខុន ៖ ចា៎!អត់ដេកផ្លូវផងម៉ោរហូតដល់បាតដំបងហ្នឹង ។

សេងគា ៖ រយៈពេលមិនបានមួយថ្ងៃផងមីង?

ខុន ៖ ចា៎!ដូចថាយើងម៉ោម៉ោង១១ថ្ងៃត្រង់ ម៉ោង១១យប់យើងមកដល់ ។

សេងគា ៖ ហើយម៉ោអាពេល៧/៩យើងម៉ោអត់ជួបយួនបាញ់គ្នាទេមីង?

ខុន ៖ អត់ទេ វាលែងមានយួនបាញ់ហើយកាលហ្នឹង ។

សេងគា ៖ ហើយតាម៉ុក គាត់រត់ម៉ោជាមួយ?

ខុន ៖ តាម៉ុក អត់ម៉ោជាមួយទេ គាត់ម៉ោនៅយូរហើយ គាត់ម៉ោនៅបាត់ដំបងយូរហើយ ។

សេងគា ៖ អ្ហូ!គាត់ទឹមប្រដែងម៉ោ?

ខុន ៖ ចា៎!កូនចៅគាត់ម៉ោតាមរយៈ ។

សេងគា ៖ អញ្ចឹង សៀន ហ្នឹងគាត់អ្នកដឹកនាំម៉ោទេ?

ខុន ៖ សៀន ហ្នឹងក៏គាត់ដឹកនាំម៉ោដែរ ។

សេងគា ៖ អ្ហូ!

ខុន ៖ ចា៎!ម៉ោដល់បាត់ដំបងនេះ គាត់ប្រជុំចែកទៅតាមសហករណ៍ម៉ង ។

សេងគា ៖ ដល់ពេលមកដល់បានគាត់ហៅប្រជុំ?

ខុន ៖ ចា៎!

សេងគា ៖ ហៅប្រជុំកន្លែងណាមីង?

ខុន ៖ ប្រជុំនៅបាត់ដំបងហ្នឹងម៉ង ។

សេងគា ៖ ប្រជុំនៅខេត្ត?

ខុន ៖ នៅកន្លែងបាត់ដំបងម៉ងអូន អាកន្លែងផ្ទះថ្មធំៗផ្សារបាត់ដំបងហ្នឹងម៉ង ប៉ុនអុំមិនសូវស្គាល់ទេកាលហ្នឹងមិនដឹងណាលិចណាកើតទេ កាលហ្នឹងម៉ោដល់ ទីក្រុងបាត់ដំបងអស់ហើយមានផ្ទះមានមនុស្សណានៅ បាត់ដំបងកាលហ្នឹងមានតែអគ្គិភាព ។

សេងគា ៖ បាទ!នៅពេលដែលគាត់ឲ្យម៉ោអញ្ចឹង តាម៉ុកហៅប្រជុំនៅខេត្ត?

ខុន ៖ ចា៎!នៅក្នុងបាត់ដំបងហ្នឹងយើងមិនដឹងថាខេត្តថាអី ប៉ុនទីក្រុងបាត់ដំបងហ្នឹងម៉ង នៅចំអាកន្លែងតួផ្សារបាត់ដំបងហ្នឹង ។

សេងគា ៖ តាម៉ុកហៅប្រជុំមីង?

ខុន ៖ ចា៎!

សេងគា ៖ ហៅប្រជុំនិយាយពីអីខ្លះមីង?

ខុន : គាត់និយាយអំពីឲ្យយើងរស់នៅជាមួយប្រជាជន យើងធ្វើម៉េចយើងនៅជាមួយប្រជាជនយើងដឹកនាំប្រជាជន យើងកុំកាចសាហាវជាមួយប្រជាជន ចា៎!ដឹកនាំប្រជាជនធ្វើការងារគ្រប់ភារៈកិច្ចទាំងអស់ដែលប្រជាជនយើងធ្លាប់ធ្វើស្អីៗអញ្ចឹងទៅ ។

សេងគា : ប៉ុន្តែអ្នកដែលទៅតាមតំបន់ផ្សេងៗមានធ្វើតាមគាត់អញ្ចឹងទេ?

ខុន : ខ្លះវាមិនធ្វើតាមគាត់ទេ ខ្លះក៏វាគោរពតាមវិន័យ ខ្លះក៏ថាបែកឆ្ងាយហើយចង់អំពើចិត្ត គេអាហ្នឹងវាមានអញ្ចឹងដែរ ដូចខ្ញុំអីគោរពតាមគាត់ គាត់ថាឲ្យយើងដឹកនាំប្រជាជនធ្វើអីយើងធ្វើហ្នឹងទៅ ។

សេងគា : ហើយកាលមីងមកដល់ហ្នឹង ប្រជុំគេចាត់ឲ្យមីងម៉ោណាវិញ?

ខុន : ខ្ញុំគេឲ្យទៅនៅព្រែកនរិណ កងរោងចក្រដូនទាវនោះ ចា៎!ដល់ហើយបានខ្ញុំមកនៅពាក់ស្បែកហ្នឹង អញ្ចឹងចេះតែនៅតៗហ្នឹង ។

សេងគា : ទៅនៅព្រែកនរិណ?

ខុន : ចា៎!

សេងគា : បាទ!នៅពេលដែលមីងនៅព្រែកនរណហ្នឹងគាត់ឲ្យមីងធ្វើអី?

ខុន : ខ្ញុំនៅប្រធានការពារដែរ ។

សេងគា : ប្រធានសហករណ៍?

ខុន : អត់ទាន់ចូលសហករណ៍ទេ ដល់នៅពាក់ស្បែកនេះបានធ្វើប្រធានសហរណ៍ហ្នឹង ដល់ព្រែកនរិណហ្នឹងនៅ ដូចថាយើងទឹមម៉ោដល់ភ្លាមអញ្ចឹង នៅការពារដដែរ ។

សេងគា : នេះហើយបានទៅពាក់ស្បែកប៉ុន្មានក៏ម៉េច?

ខុន : ចា៎!ព្រែកនរិណហើយអញ្ចឹងទៅ បានខ្ញុំទៅពាក់ស្បែកក្រោយនេះ ប៉ុនអូនឯងអត់សួរអស់អញ្ចឹងខ្ញុំភ្លេចនិយាយ ។

សេងគា : អ្ហូ!អញ្ចឹង?

ខុន : ចា៎!អញ្ចឹងវាបញ្ចាស់បន្តិចហើយ ។

សេងគា : បាទ!

ខុន : អាហ្នឹងខ្ញុំនៅការពារដែលទេ ។

សេងគា : បាទ!អញ្ចឹងនៅព្រែកនរិណហ្នឹងនៅការពារ?

ខុន : ចា៎!នៅការពារនៅមិនទាន់ម៉ោកងសហករណ៍ ដល់ខ្ញុំនៅហ្នឹងយូរពេកទៅដូចថាកងការពារច្រើនពេកអញ្ចឹងទៅ គេឲ្យការពារតាម ។

សេងគា ៖ នៅព្រែកនរិណនៅម្តុំណា នៅកន្លែងណាមួយ ឃុំគេម៉ង?

ខុន ៖ អត់ស្គាល់អស់ទេអូន ដឹងតែព្រែកភោក ព្រែកប្រាជ្ញ ព្រែកនរិណហ្នឹងម៉ង ដឹងតែអញ្ចឹង ។

សេងគា ៖ អ្ហូ!៣នាក់ហ្នឹង នៅទាំងអស់ការពារហ្នឹង?

ខុន ៖ ចា៎!នៅហ្នឹងម៉ង ដើរការពារហ្នឹង ដើរបានចំនួនម៉ាអាទិត្យទេកាលហ្នឹងនោះ ។

សេងគា ៖ បានម៉ាអាទិត្យ កាលហ្នឹងទៅប៉ុន្មាននាក់?

ខុន ៖ គ្នាប្រហែលជា១០នាក់ ។

សេងគា ៖ ១០នាក់មានមិត្ត រ៉េត ទៅជាមួយដែរ?

ខុន ៖ រ៉េត ហ្នឹងអត់បានទៅហ្នឹងទេ គេបែកហើយ ។

សេងគា ៖ ចុះមីងទៅ គេឲ្យមីងអ្នកកាន់កាប់ ជាមេក្រុម?

ខុន ៖ ខ្ញុំមេក្រុមគេដែរ ប៉ុនគ្រាន់ថាយើងជំនួយជាមួយមេគេមួយទៀតណាស់ ប៉ុនឥឡូវខ្ញុំភ្លេចឈ្មោះគាត់ហើយមេហ្នឹងមិនដឹងគាត់ទៅនៅត្រង់ណាទេ ។

សេងគា ៖ ការពារពភូមិហ្នឹង ព្រែកជ្រក ព្រែកនរិណ ស្វាយជ្រុំ?

ខុន ៖ អត់ទេ អត់ដល់ហ្នឹងទេ ។

សេងគា ៖ ព្រែកក្រូច ព្រែកនរិណ ព្រែកអីមួយទៀត?

ខុន ៖ ព្រែកក្រូច ព្រែកនរិណ ព្រែកកញ្ចែងហ្នឹង ។

សេងគា ៖ គេឲ្យការពារអីគេកាលហ្នឹង មានអីម៉ោ?

ខុន ៖ អត់ដឹងថាគេឲ្យការពារអីទេ គ្រាន់តែខ្លាចលមានបងប្អូនណាធ្វើសកម្មភាពអីខុសច្បាប់ខុសអីអាហ្នឹងត្រូវចាប់គេឯង ។

សេងគា ៖ ចុះមីងដែលខុសឬអត់កាលហ្នឹង?

ខុន ៖ អត់មាន គ្មានអ្នកណាដែលធ្វើខុសធ្វើអី ។

សេងគា ៖ មីងមានស្គាល់អីប្រធានអី?

ខុន ៖ អត់ទេ អត់ទាន់ស្គាល់ទេអូន នៅទេអត់ទាន់ស្គាល់សុទ្ធម៉ង ។

សេងគា ៖ គេអត់មានណែនាំយើងពីលើទេ?

ខុន ៖ ពីលើគេអត់ទាន់ណែនាំឲ្យយើងទេ យើងទៅវាពេលវេលាខ្លីពេក ដូចថាគ្រាន់ថាយើងចុះទៅការពារអញ្ចឹងទៅ ប៉ុនយើងមិនដឹងថាប្រធានភូមិគេឈ្មោះអីទេ យើងទៅសហការជាមួយប្រធានភូមិគេហើយ ប៉ុនគ្រាន់តែថាភូមិគេឈ្មោះអីៗយើងមិនទាន់ស្គាល់

ទៅរយៈខ្លីណាស់ ហើយនៅវេន្ទេនលិចកើតអត់ទាន់ដឹងលិចកើតផងខ្ញុំ គ្រាន់តែថា ហ៎ ទៅលិចៗ ទៅកើតៗ ទៅតាមគេហ្នឹង ។

សេងគា ៖ ភូមិហ្នឹងម៉េចដែលហូបចុកអត់អីទេ?

ខុន ៖ ហូបចុកអីប្រជាជនកាលហ្នឹងខ្ញុំទៅកំពុងតែបបរវាល់វែកទេ ។

សេងគា ៖ អ្ហ៎! វែលវែកដែរ?

ខុន ៖ ចា៎! បបរវាល់វែកទេ ។

សេងគា ៖ អត់មានគេធ្វើបាបធ្វើអីទេ?

ខុន ៖ អត់មានឃើញធ្វើអីទេ ព្រោះខ្ញុំទៅហ្នឹងឃើញថា ខ្ញុំទៅដល់ដំបូងឃើញបបរវាមាំថ្ងៃហ្នឹងហូប៣ពេល ប៉ុន្តបានក្នុង១នាក់បានតែវែកទេ ។

សេងគា ៖ អញ្ចឹងមីងទៅបានតែមាំអាទិត្យទេ?

ខុន ៖ ចា៎! បានមាំវែកៗទេ ។

សេងគា ៖ អញ្ចឹងពេលមីងបានហូបបាយហូបអី?

ខុន ៖ ខ្ញុំអត់ទេ ហូបបបរជាមួយគេដែរ ។

សេងគា ៖ ហូបបបរជាមួយគេដែរ?

ខុន ៖ ចា៎! ព្រោះខ្ញុំតាំងចិត្តថាប្រជាជនហូបអីខ្ញុំហូបហ្នឹង តែខ្ញុំហូបបបរជាមួយប្រជាជនហ្នឹងដែរ ។

សេងគា ៖ ប៉ុន្តែបើមីងចង់ហូបបាយក៏បានដែលកាលហ្នឹង?

ខុន ៖ ចា៎! បើខ្ញុំហូបបាយក៏មិនដឹងហូបណាដែល បើខ្ញុំហូបជាមួយសហករណ៍គេហ្នឹងដែរ ។

សេងគា ៖ ប្រធានភូមិគេអត់រៀបចំអីឲ្យទេ?

ខុន ៖ អត់ទេ! ទោះរៀបក៏ខ្ញុំអត់ហូបដែរ ។

សេងគា ៖ អត់ស្គាល់គណៈភូមិ គណៈឃុំគេទេ?

ខុន ៖ អត់ៗទាន់ស្គាល់ទាំងអស់ ។

សេងគា ៖ ដល់ពេលមីងនៅបានមាំអាទិត្យហើយ គេបញ្ជូនទៅណា?

ខុន ៖ ដូចខ្ញុំនិយាយមិញអញ្ចឹង ដល់ហើយខ្ញុំក៏ម៉ោពាក់ស្បែកនេះម៉ោ ដល់ម៉ោពាក់ស្បែកនេះបានមានភូមិ ឃុំគេម៉ងហ្នឹង ។

សេងគា ៖ អ្នកណា តាម៉ុកអ្នកបញ្ជូនដែរ?

ខុន ៖ លែងតាម៉ុកហើយ ។

សេង៉គា ៖ អ្នកណាគេ?

ខុន ៖ គូរ៉េត គាត់នាំខ្ញុំម៉ោវិញហើយ ។

សេង៉គា ៖ មិត្តនារី រ៉េត ហ្នឹង?

ខុន ៖ មិនមែននារីទេ គាត់ក្រុមដើរយុវជនទេ រ៉េន ហ្នឹងនាំគ្នាម៉ោពាក់ស្បែកដែរ ។

សេង៉គា ៖ មិត្ត រ៉េត ហ្នឹងគាត់អ្នកណាគេ?

ខុន ៖ រ៉េត ហ្នឹងគាត់ធ្វើធំដែរឥឡូវគាត់ស្លាប់បាត់ហើយ ។

សេង៉គា ៖ ធ្វើធំនៅតាកែវហ្នឹង?

ខុន ៖ ធ្វើនៅនេះ នៅខ្មែរក្រហមហ្នឹងដែរ ។

សេង៉គា ៖ គាត់ធ្វើអីគេ?

ខុន ៖ រ៉េត ហ្នឹងគាត់ធ្វើវរៈសេនាធំ គាត់អ្នកនាំខ្ញុំម៉ោ គាត់ត្រូវក្មួយខ្ញុំ ប្រពន្ធគាត់ ហើយគាត់ដឹងថាខ្ញុំត្រូវម្តាយមីង តាម៉ុកបញ្ជូនគាត់ម៉ោពាក់ស្បែកហ្នឹងក៏គូរ៉េតហ្នឹងយកខ្ញុំម៉ោតាមគាត់ម៉ោ ។

សេង៉គា ៖ ជាប្រធានវរៈសេនាធំ?

ខុន ៖ ចា៎! ឲ្យធ្វើប្រធានសហករណ៍ហ្នឹងទៅ ។

សេង៉គា ៖ ត្រូវជាក្មួយប្រសារ?

ខុន ៖ មិត្តទូចហ្នឹងត្រូវជាក្មួយជីដូនមួយខ្ញុំ ប្រពន្ធគូរ៉េតហ្នឹង ។

សេង៉គា ៖ អញ្ចឹងក្មួយប្រសារជីដូនមួយ?

ខុន ៖ ចា៎! គាត់ក៏ដឹងអញ្ចឹងគាត់ក៏យកខ្ញុំម៉ោពាក់ស្បែកហ្នឹងទៅ ក៏គាត់ចាត់តាំងខ្ញុំឲ្យធ្វើប្រធានក្រុមហ្នឹងទៅ គូរ៉េតហ្នឹង ឈប់ឲ្យខ្ញុំការពារហើយហ្នឹង នៅពាក់ស្បែកហ្នឹង ។

សេង៉គា ៖ ដល់បានដឹងទៅក៏ចាត់ឲ្យអីហ្នឹង?

ខុន ៖ ធ្វើប្រធានសហករណ៍ ។

សេង៉គា ៖ មកធ្វើប្រធានសហករណ៍វិញ?

ខុន ៖ ចា៎!

សេង៉គា ៖ សហករណ៍នៅណា នៅភូមិ?

ខុន ៖ នៅពាក់ស្បែកហ្នឹងម៉ង ។

សេង៉គា ៖ ចុះធ្វើដល់ឆ្នាំណាដែរ?

ខុន ៖ ធ្វើបានខ្ទីដែរព្រោះ ។

សេង៉គា ៈ ហើយចុះទ័ពទៅជាមួយហ្នឹងអត់បានម៉ោជាមួយទេ ប៉ុន្មានទ១០នាក់ទៅជាមួយហ្នឹងអត់ទេ?

ខុន ៈ អត់ទេ!បែកគ្នាអស់ហើយ ។

សេង៉គា ៈ ម៉ោតែឯងទេ?

ខុន ៈ ចា៎!ម៉ោតែឯងទេ បែកគ្នាបន្តៗ ម៉ោនៅបានប៉ុន្មានខែហ្នឹងអូនអើយ ម៉ោយួនបុកចូលពេញប្រទេសកម្ពុជាយើងទៅ ខ្ញុំចេញពីសហករណ៍ពាក់ស្បែកហ្នឹង ចេញហើយចាប់ផ្តើមចេញហើយ នៅបានបន្តិចទេ ព្រោះសុខទុកជាមួយប្រជាជនខ្ញុំដើរបានច្រើន ណាស់ដើរជាមួយប្រជាជនហ្នឹងរហូតដល់ប្រជាជនហ្នឹងគាត់សួរយោបល់ខ្ញុំដែរ គាត់ថាកូនៗម៉េចកូនឯងហ៊ានហូបបាយជាមួយពុកម៉ែ អត់ខ្លើមពុកម៉ែទេ គាត់សួរខ្ញុំកន្លែងហ្នឹងមួយដែរណាស់ ។

សេង៉គា ៈ បាទ!

ខុន ៈ ចា៎!ខ្ញុំថាខ្ញុំខ្លើមអីបើពុកម៉ែខ្ញុំហូបស្វាមួរដូចតែពុកម៉ែដែរហ្នឹង ហើយខ្ញុំទៅខ្លើមអីខ្ញុំថាអញ្ចឹង ។

សេង៉គា ៈ បាទ!

ខុន ៈ ម៉េចអញ្ចឹងគេមុនៗម៉ោគេអត់ហូបបាយជាមួយប្រជាជនទេ គេមិនហូបបាយជាមួយប្រជាជនទេគេខ្លើមប្រជាជនគេចង់ហូបគោៗ គេចង់ហូបសាច់មាន់ៗ ស្រេចតែលើគេ ទេ គេហូបបាយផ្សេងជាមួយប្រជាជន ចុះចំណែកតែកូនឯងមួយម៉េចក៏មកហូបបាយជាមួយពុកម៉ែអញ្ចឹង ។

សេង៉គា ៈ អាហ្នឹង៧៩ហើយ?

ខុន ៈ ចា៎!អាហ្នឹងដែលយើងចូលមកនៅពាក់ស្បែកហ្នឹង ។

សេង៉គា ៈ បាទ! ៧៩ហ្នឹងនៅពាក់កណ្តាលខែឬក៏ខែណាដែរ?

ខុន ៈ ខ្ញុំគ្រាន់តែខែច្រូតស្រូវ យួនបុកហើយ ។

សេង៉គា ៈ ខែច្រូតស្រូវខែមួយ?

ខុន ៈ ខែ១១ហ្នឹង ហ្នឹងយើងពុងពេញច្រូតស្រូវហើយហ្នឹង ដើមពីខែស្ទូងម៉ោស្ទូងនៅ ។

សេង៉គា ៈ អ្ហូ!អត់ទាន់ដាច់ទេមីង?

ខុន ៈ ចា៎!អត់ទាន់ដាច់ទេ ដូចថាយើងម៉ោដល់អញ្ចឹងយើងមិនសាបចាប់ផ្តើមសាបចាប់ផ្តើមស្ទូងហើយណាស់ ។

សេធគា ៖ ព្រោះអីនៅភ្នំពេញអាឆ្នាំ៧៩ ថ្ងៃទី៧ មករា ដាច់ហើយ តែខាងនោះអត់ទាន់ដាច់ ទេ?

ខុន ៖ ហ្នឹងហើយខ្ញុំនៅនោះនៅឡើយ ដូចខ្ញុំប្រាប់ថាខ្ញុំនៅស្រែអំបិលនៅឡើយ ខ្ញុំប្រាប់ថាខ្ញុំនៅភាគស្រែអំបិលខ្ញុំទឹមឡើងម៉ោឆ្នាំ៧៨ហ្នឹងជិតចូល៧៩ហ្នឹងហើយហ្នឹង ដល់នេះខ្ញុំម៉ោនៅជាមួយគាត់អញ្ចឹងទៅ ក៏គាត់ថាកូនៗឯងម៉េចក៏ធ្វើអញ្ចឹងអត់ហូបបាយផ្សេងពីម៉ែកូនឯងហូបបាយផ្សេងទៅ ខ្ញុំថាទោះម៉េចក៏ខ្ញុំអត់ហូបបាយផ្សេងជាមួយពុកម៉ែដែរ ខ្ញុំរស់នៅក្រោមការដឹកនាំរបស់ពុកម៉ែ ប៉ុន្តែខ្ញុំដឹកនាំពុកម៉ែមែនពិត ប៉ុន្តែខ្ញុំវ័យខ្ញុំនៅក្មេងដូចជាកូនពុកម៉ែដែរ ព្រោះខ្ញុំមិនអាចទៅធ្វើអញ្ចឹងបានទេ ឥឡូវពុកម៉ែធ្វើអី ដែលផលដំណាំអីដែលពុកម៉ែដាំបានពីសង្គមពីមុនម៉ោម៉េច ពុកម៉ែធ្វើអញ្ចឹងទៅ ។

សេធគា ៖ បាទ!

ខុន ៖ ចាំ!ខ្ញុំរៀនសូត្រតាមដែលពុកម៉ែខ្ញុំបញ្ជាទេ ។

សេធគា ៖ អញ្ចឹងគណៈស្រុកគណៈភូមិអីគេអត់ថាទេ?

ខុន ៖ អត់ថាទេ ។

សេធគា ៖ ពេលសម័យហ្នឹងគេយកទៅវៃមីង?

ខុន ៖ ចាំ!អត់មានថាអីទេ ព្រោះខ្ញុំធ្វើបានៗតាមគាត់ផល ហើយដល់ត្បាញក្រមារ ត្បាញអីតាមសហករណ៍អញ្ចឹងទៅ ឧទាហរណ៍បានក្រមារ៣០០ក្រមារអញ្ចឹងទៅ យើងដាក់រាយការណ៍តែ១០០អីទៅ ទុក២០០ក្រមារឲ្យប្រជាជនយើងប្រើប្រជាជនក្នុងភូមិពាក់ស្បែកហ្នឹង ចាំ!យើងមិនរាយការណ៍ឲ្យគាមហ្នឹង ។

សេធគា ៖ រហូតដល់ខែច្រូតស្រូវមីង?

ខុន ៖ ចាំ!រហូតដល់ខែច្រូតស្រូវនឹងបាន កំពុងតែបោកប៉ែនបានខ្លះហ្នឹងបានច្រូតជាមួយប្រជាជនបានម៉ាចំនួនហ្នឹង ទាល់សភាពការអត់ស្រួលហ្នឹងក៏យើងចូល ចេញពីពាក់ស្បែកហ្នឹងម៉ោហើយ ។

សេធគា ៖ មីងចេញម៉ោតែឯង?

ខុន ៖ ចាំ!ចេញម៉ោជាមួយ ។

សេធគា ៖ ចុះអនុប្រធានមីងឈ្មោះ?

ខុន ៖ ចាំ?

សេធគា ៖ អនុប្រធានសហករណ៍?

ខុន ៖ អនុប្រធានសហករណ៍ហ្នឹងឈ្មោះ ពូ សៀម ឥឡូវក៏គាត់ស្លាប់បាត់ដែរហើយ គាត់នៅពាក់ស្បែកហ្នឹង ប៉ុនគាត់រត់ម៉ោសាលាក្រៅនេះ សាលាក្រៅយើងប៉ៃលិននេះ ប៉ុនឥឡូវគាត់ស្លាប់ដែលហើយ ជួបគាត់ កាលជំនាន់នេះហ្នឹងក៏ជួបគាត់ដែរ ប៉ុនឥឡូវគាត់ស្លាប់ហើយ ហ្នឹងស្រុកភូមិគេនៅហ្នឹងម៉ង ។

សេងគា ៖ បាទ!

ខុន ៖ ចា៎!ស្រុកភូមិគេនៅពាក់ស្បែកហ្នឹង ។

សេងគា ៖ អញ្ចឹងមីងរត់ម៉ោតែឯងទេ?

ខុន ៖ ដល់ខ្ញុំរត់ម៉ោ ចូលកងទ័ព ។

សេងគា ៖ ចូលទ័ពណា?

ខុន ៖ ចូលទ័ព ខ្ញុំនៅកងរថក្រោះ ។

សេងគា ៖ កងរថក្រោះនៅណាវិញ?

ខុន ៖ ចា៎!កងរថក្រោះយើងហ្នឹងមិននៅការពារកន្លែង ដូចថាកាលហ្នឹងជាអគ្គភាពគេមិនដឹងប៉ុន្មានៗ ហៅថាកងរថក្រោះៗអញ្ចឹងម៉ង ប៉ុនប្រធានរថក្រោះគេហ្នឹងឈ្មោះ តាដល ដឹងតែប្រធានកងឈ្មោះ បូដល ប៉ុនវាបែកគ្នារហូតម៉ោមិនដឹងទៅនៅណាណីទេ ខ្ញុំចូលកងទ័ពវិញទៀតហ្នឹង ។

សេងគា ៖ មីងក៏រត់ម៉ោចូលកងរថក្រោះ?

ខុន ៖ ចា៎!ចូលកងរថក្រោះវិញហើយ ។

សេងគា ៖ កងរថក្រោះនៅកន្លែងណាវិញ?

ខុន ៖ នៅគ្រប់កន្លែងអូន ដល់ម៉ោដល់អញ្ចឹងទៅ យើងមិនមានទីតាំងអី ។

សេងគា ៖ ចូលម៉ោនៅជំបូងនៅកន្លែងណា?

ខុន ៖ ចូលម៉ោនៅជំបូងខ្ញុំនៅស្តៅ ។

សេងគា ៖ នៅស្រុកស្តៅ?

ខុន ៖ ចា៎!

សេងគា ៖ ឃុំស្តៅ ស្រុកស្តៅ?

ខុន ៖ ប៉ុនយើងមិននៅក្នុងភូមិក្នុងអីគេទេ យើងគ្រាន់តែស្នាក់នៅ ។

សេងគា ៖ ហើយម៉េចបានគេឲ្យចូលមីង?

ខុន ៖ ចូលទ័ពនេះហ្នឹង?

សេងគា ៖ បាទ!វត់ម៉ោអញ្ចឹង?

ខុន ៖ ចុះយើងអន្តភាពយើងស្គាល់គ្នាអញ្ចឹង ។

សេងគា ៖ ស្គាល់អ្នកណាគេ?

ខុន ៖ ស្គាល់ពូ វុន ស្គាល់អី ។

សេងគា ៖ ឈ្មោះអីគេ វុន ។

ខុន ៖ គ្នាយើងពីមុនម៉ោ នារីៗយើងធ្លាប់នៅស្រែអំបិលពីមុនម៉ោហ្នឹង ។

សេងគា ៖ នារី ឈ្មោះ វុន?

ខុន ៖ នារីមិនមែនឈ្មោះ វុន ទេពូដែលឈ្មោះ វុន ហើយនារីៗឈ្មោះបងរី ហើយច្រើនណាស់ ហើយក៏នាំគ្នាថាយើងចូលក្នុងកងទ័ពទាំងអស់គ្នាទៅ ។

សេងគា ៖ ឈ្មោះ វុន កាលហ្នឹងគាត់ធ្វើអីទេ?

ខុន ៖ គាត់ធ្វើកងវរយដែរ ។

សេងគា ៖ ប្រធានកងវរយ?

ខុន ៖ ចាំ!

សេងគា ៖ កាន់វេថក្រោះមីង?

ខុន ៖ ចាំ!

សេងគា ៖ គាត់អ្នកស្រុកជាមួយមីងដែរ?

ខុន ៖ អត់អ្នកស្រុកជាមួយគ្នាទេ គ្រាន់តែធ្លាប់ធ្វើទ័ពធ្វើអី ធ្លាប់ស្គាល់គ្នានៅបាត់ដំបង តែនៅអន្តភាពផ្សេងគ្នា ។

សេងគា ៖ អ្ហូ!ស្គាល់គ្នាទៅក៏ឲ្យគេចូលទៅមីង?

ខុន ៖ ចាំ!នៅរហូតដល់ខ្ញុំបែកពីគាត់វិញ ដល់យួនបុកនៅក្រញ៉ូងនេះនៅសាញនេះ ក្រញ៉ូងសាញយើង ។

សេងគា ៖ ដល់ពេលនៅហ្នឹងហើយ គេចល័តទៅណាទៀត?

ខុន ៖ ដល់នេះខ្ញុំម៉ោនៅដងទង់ ចេញពីស្ដៅៗពីស្ដៅម៉ោ នៅដងទង់ ។

សេងគា ៖ នៅហ្នឹងបានប៉ុន្មានថ្ងៃ?

ខុន ៖ នៅស្ដៅហ្នឹង?

សេងគា ៖ បាទ!

ខុន ៖ នៅស្ដៅហ្នឹងបានមាំអាទិត្យ ។

សេងគា ៖ ម៉ោនៅក្រញូង?

ខុន ៖ អត់ទេឈប់សិន មិនទាន់ដល់ទេ ដល់ខ្ញុំចេញពីស្តៅហ្នឹងម៉ោខ្ញុំនៅរោងចក្រភូមិគល់ ។

សេងគា ៖ រោងចក្រភូមិគល់?

ខុន ៖ ចា៎!សុទ្ធតែស្នាក់នៅទាំងអស់ហើងហ្នឹង ។

សេងគា ៖ ភូមិគល់ហ្នឹងនៅស្រុកអីគេ?

ខុន ៖ មិនដឹងស្រុកអីទេនៅក្នុងបាត់បងហ្នឹងដដែល រោងចក្រភូមិគល់ហ្នឹង ដល់នេះត្រឡប់ម៉ោស្តៅវិញទៀតហើយ អញ្ចឹងយួនយើងនៅសុទ្ធ ត្រឡប់ម៉ោនៅស្តៅអញ្ចឹងហើយបានទៅនៅស្នាក់ការ ។

សេងគា ៖ នៅភូមិគល់ហ្នឹងបានប៉ុន្មានថ្ងៃ?

ខុន ៖ បាន៣-៤ថ្ងៃទេអូន អត់បានយូរទេ ពេលវេលាដែលយើងសុទ្ធតែក្នុងនេះហ្នឹង ។

សេងគា ៖ បាន៤ថ្ងៃក៏ត្រលប់មកនៅស្តៅវិញ?

ខុន ៖ ចា៎!ត្រឡប់មកនៅស្តៅវិញទៀត ។

សេងគា ៖ កាលហ្នឹងនៅកងវរថក្រោះដូចគ្នា?

ខុន ៖ ចា៎!នៅកងវរថក្រោះដូចគ្នា អត់មានប្តូរទេ ។

សេងគា ៖ កាលហ្នឹងមានគ្នាប៉ុន្មាននាក់នៅកងវរថក្រោះហ្នឹង ?

ខុន ៖ ច្រើនដែលហ្នឹងប្រហែល ។

សេងគា ៖ រាប់រយរាប់ពាន់នាក់?

ខុន ៖ ចា៎!អត់ដល់ពាន់ទេ ប្រហែលជាចំនួនរយនាក់អីជាងទេ ។

សេងគា ៖ ប្រធានរថក្រោះឈ្មោះអីគេ?

ខុន ៖ ប្រធានក្រុមហ្នឹង?

សេងគា ៖ បាទ!

ខុន ៖ ឈ្មោះផល ដូចខ្ញុំប្រាប់លើមុនថាឈ្មោះ ផលហ្នឹង ។

សេងគា ៖ អ្ហូ!ប្រធានរថក្រោះមិនមែនឈ្មោះ រុន ទេឈ្មោះផលវិញ?

ខុន ៖ រុន ហ្នឹងកងវរយ ប្រធានគេឈ្មោះលោក ផលនោះខ្ញុំប្រាប់ថាលោក ផលមិញ ហើយដល់នេះបានចេញពីកំពុងគល់ហ្នឹងមកស្តៅទៀតហើយ ដល់ថាយួនបុកស្តៅទៀតហើយ អាហ្នឹងគេថាយួនបុកស្តៅខ្ញុំម៉ោនេះទៀតនេះ ឥឡូវខ្ញុំម៉ោនៅដងទង់វិញទៀត ទៅត្រឡប់លិចហ្នឹង ខ្ញុំត្រឡប់វៃលិចវៃកើតហ្នឹង ។

សេងគា ៖ ទៅ៣-៤ថ្ងៃៗម៉ោវិញ?

ខុន ៖ ចាំ!២-៣ៗថ្ងៃៗទេ ។

សេងគា ៖ ម៉ោដងទង់?

ខុន ៖ ចាំ!

សេងគា ៖ ដងទង់អត់ដឹងភូមិអីឃុំអីទេ ដឹងតែដងទង់?

ខុន ៖ អត់ទេៗដឹងតែដងទង់ហ្នឹងម៉ង់ ។

សេងគា ៖ បានប៉ុន្មានថ្ងៃដែរ?

ខុន ៖ នៅហ្នឹងបានរយៈពេលប្រហែលជា១០ថ្ងៃដែរ ។

សេងគា ៖ បាញ់គ្នាដែលមីង?

ខុន ៖ កាលហ្នឹងបាញ់ ខ្ញុំនៅក្រោយនេះទេ គេបាញ់នៅមុខនោះ ខ្ញុំនៅក្រោយទេ ។

សេងគា ៖ ការហូបចុកអីអត់អីទេ?

ខុន ៖ ការហូបចុកអីអត់អីទេសំបូរណាស់ ព្រោះយើងធ្វើទ័ព ។

សេងគា ៖ ដល់ពេលនៅហ្នឹងហើយទៅណាទៀត?

ខុន ៖ រួចម៉ោ ចេញពីអាហ្នឹងម៉ោគេឲ្យទៅវៃនៅភ្នំសំពៅនេះ កងទ័ពពួកយើងកងទ័ពពួកខ្ញុំហ្នឹងគេឲ្យទៅវៃភ្នំសំពៅ ពួកខ្ញុំគេឲ្យនៅស្នាក់ការ ។

សេងគា ៖ អ្នកណាឲ្យទៅវៃ ពូ ផលហ្នឹង?

ខុន ៖ អាហ្នឹងវាអើមានមេមានតែពូផលហ្នឹងឯង ទៅវៃហ្នឹងពួកខ្ញុំស្នាក់នៅបាណន់ៗ ។

សេងគា ៖ នៅទីស្នាក់ការនៅបាណន់?

ខុន ៖ ចាំ!

សេងគា ៖ ចេញពីបាណន់ហ្នឹងហើយ បានប៉ុន្មានថ្ងៃបាន?

ខុន ៖ ដល់ចេញពីបាណន់ហ្នឹងហើយ នៅបានប្រហែលម៉ាអាទិត្យ ម៉ាអាទិត្យជាងនៅមិនបានយូរទេ ព្រោះសភាពការអត់ស្រួលៗអញ្ចឹងនៅមិនបានយូរទេ ដកលិចដកកើត បានរួចម៉ោ ម៉ោនៅភ្នំបាដេរ ។

សេងគា ៖ ប្រយុទ្ធខ្លាំងមីងមានបានទៅប្រយុទ្ធទេ?

ខុន ៖ អត់បានទៅទេ ទៅតែពូៗទេ យើងនៅចាំតែដឹកជញ្ជូនរបួស ។

សេងគា ៖ មីងដឹកជញ្ជូន?

ខុន ៖ ចាំ!ដូចថាមានរបួសមានអីអញ្ចឹងទៅ យើងចាំតែដឹកជញ្ជូនមកពេទ្យ ។

សេង៉គា ៖ កាលហ្នឹងមានស្លាប់ច្រើនទេ?

ខុន ៖ ស្លាប់ច្រើនណាស់ដែរ ។

សេង៉គា ៖ ផល ហ្នឹងអត់អីទេ?

ខុន ៖ ផល ហ្នឹងអត់អីទេ ។

សេង៉គា ៖ នៅរាល់ថ្ងៃទេឥឡូវ?

ខុន ៖ នៅសំឡូតនោះ ប៉ុនមិនដឹងគាត់ស្លាប់ឬនៅរស់ទេ ព្រោះបែកគ្នា ចាំខ្ញុំនិយាយប្រាប់មិនទាន់ដល់ហ្នឹងទេ ។

សេង៉គា ៖ ដល់ពេលអញ្ចឹងហើយអ្នកណាទៀត?

ខុន ៖ ដល់ពេលហ្នឹងហើយត្រឡប់ម៉ោនៅក្រញ៉ូងហ្នឹងហើយ អាក្រញ៉ូងសាញបៀតដងទន់ហ្នឹងទៀតហើយ ទៅវៃនៅក្រញ៉ូងហ្នឹងហើយ ។

សេង៉គា ៖ បានប្រហែលជាប៉ុន្មានថ្ងៃទៅវៃហ្នឹង វៃជាមួយទាហានវៀតណាមឬក៏?

ខុន ៖ វៃយួនជាមួយយួនហ្នឹង ។

សេង៉គា ៖ ទៅវៃបានប្រហែលប៉ុន្មានថ្ងៃ?

ខុន ៖ វៃបានមួយយប់មួយថ្ងៃ ដល់ហើយអារថក្រោះខ្ញុំនោះវានៅមុខវាអាចឆេះ២-៣គ្រឿងទៅ នៅសល់៣គ្រឿងមកចាក់ប្រេងនៅអូរាំងឪន មកចាក់ប្រេងនៅហ្នឹង ក៏ពួកខ្ញុំអត់ទៅសមរភូមិវិញទេ ពួកគ្នាខ្ញុំអត់ឲ្យទៅ ឲ្យនាំពួកកម្លាំងដែលប៉ុន្មាននាក់ហ្នឹងនាំប្រជាជនយើងដែលរាប់ពាន់នាក់ដែលរត់មានរទេះគោ មានកង់ មានដើរអីហ្នឹងបុកព្រៃឲ្យប្រជាជនយើងរត់រទេះ៣គ្រឿងហ្នឹង ។

សេង៉គា ៖ បាទ!

ខុន ៖ ដើម្បីឲ្យឡានឲ្យអីបើកតាមក្រោយ ហើយរថក្រោះហ្នឹងយើងអត់រត់ចេញទេ ខ្លាចយួនរត់ចេញរទេះ រត់ហ្នឹងប្រហែលរយៈ២ថ្ងៃដែល ដល់យួនវាដេញយើងកិតៗៗទៅយើងក៏អស់ម៉ាស៊ូតចាក់រថក្រោះហើយ អញ្ចឹងក៏បររថក្រោះហ្នឹងទម្លាក់ជ្រោះៗទាំងអស់ទាំង៣គ្រឿងហ្នឹង ។

សេង៉គា ៖ បាទ!

ខុន ៖ ដល់នេះយើងដោះយកកូនជ្រូនអាក្រោះហ្នឹងទុកអស់ហើយ ហើយយើងពួនទៅក្បែរៗហ្នឹងដែរ ដល់នេះយួនវាបុកម៉ោៗតាម វាកៀរប្រជាជនយើងដែរអស់ផ្លូវរត់ហ្នឹងនោះ

វាកៀរប្រជាជនមកចំនួនមកវិញ មកក្នុងប្រទេសយើងវិញមិនដឹងវាធ្វើបាបមិនធ្វើបាប យើងមិនបានឃើញទេ ។

សេងគា ៖ ចុះនៅពេលដែលអស់ហ្នឹង យើងបើកទម្លាក់ជ្រោះៗនៅកន្លែងណា?

ខុន ៖ ជ្រោះហ្នឹងយើងអត់ដឹង អត់ដឹងកន្លែងទេ ។

សេងគា ៖ ប៉ុន្តែនៅកៀរៗហ្នឹងទេ?

ខុន ៖ ចាំ!នៅក្នុងព្រៃហ្នឹងហើយ ពេញក្នុងស្រុកប្រទេសខ្មែរយើងហើយ ប៉ុនដឹងកន្លែងណា ក្នុងខេត្តសំឡូតហ្នឹង មិនដឹងកន្លែងណាក្នុងសំឡូត ក្រញូងស្សាញហ្នឹងសំឡូតហើយ ហើយដល់នេះពួកខ្ញុំក៏អស់ផ្លូវអស់អីប្រជាជនមួយចំនួនចេះតែមកតាមពួកខ្ញុំហើយៗ ។

សេងគា ៖ ចុះមិត្តផលហ្នឹងគេចាប់បានទេ?

ខុន ៖ ផលអត់ចាប់បានទេ គាត់មករហូតនៅសំឡូតរហូត ចាំ!គាត់នៅក្នុងសំឡូតហ្នឹងរហូត ហ្នឹង ហើយខ្ញុំនេះបានបែកពីពួផល ហ្នឹងបែកចំនួនមកកងហារ បែកចេញពីគេប្រហែល មកកងហារ បែកវង្វេងផ្លូវគ្នារកផ្លូវគ្នាអត់ឃើញទេ ។

សេងគា ៖ អ៊ីកាន់ទ័ពខ្លួនឯងគេចម៉ង?

ខុន ៖ គេកាន់ហើយ យើងកូនក្រុមគេ គេមានប្រធានក្រុមអញ្ចឹងគេមេយើងមួយទៀត ។

សេងគា ៖ មេគេឈ្មោះអី?

ខុន ៖ ភ្លេចឈ្មោះគាត់ហើយ ប៉ុនដឹបែក ។

សេងគា ៖ ដល់បែកគ្នាទៅក៏គេចទៅ?

ខុន ៖ ចាំ!

សេងគា ៖ គេចាប់បាន?

ខុន ៖ អត់ចាប់បានទេ យើងរត់ៗពីហ្នឹងមកបែកៗមកដល់ពួកយួននោះវាអូសរថក្រោះយើង យើងនៅហ្នឹងក្បែរហ្នឹងយើងពួនអត់ហានឲ្យវាឃើញទេ ដល់វាអូសរថក្រោះយើងបាន អស់វាវិលត្រឡប់មកក្រញូងស្សាញយើងវិញពួកយួនហ្នឹង ហើយយើងចេះតែបុកវា អត់ចាប់បានប៉ុន្មានហ្នឹង ពួកខ្មែរក្រហមហ្នឹងវាអត់ចាប់ពួកយើងបានទេ ពួកខ្ញុំហ្នឹងរត់ ចូលមកដីថៃឡើងភ្នំកាត់ភ្នំប្រហែលជាមកអាទិត្យជាងនោះកាលហ្នឹងបានមកដល់ថៃ ។

សេងគា ៖ មីងរត់ម្នាក់ឯង?

ខុន ៖ អត់ទេ ខ្ញុំរត់ចូលចាន់នារីនេះ ។

សេងគា ៖ អញ្ចឹងរត់រហូតដល់ឆ្នាំ៨០ប៉ុន្មានកាលហ្នឹង?

ខុន ៖ មិនដឹង៨០ប៉ុន្មានទេ យូរដែរមិនចាំទេ ។

សេងគា ៖ ពី៧៩ម៉ោរត់រហូត?

ខុន ៖ រត់ចេញពីកម្ពុជាយើងម៉ោរត់រហូតហ្នឹង រត់កាត់ប្រហែលចំនួនមាឺ ដើរប្រហែលមាឺ អាទិត្យដែរហ្នឹងទំរាំមមកដល់ដីថៃនេះ បានចូលដល់ដីថៃឃើញប្រជាជនកាប់ព្រៃហ្នឹង បានយើងសម្រុកចូល សម្រុកចូលកាំភ្លើងអីវ៉ាន់ ម្នាក់ៗសុទ្ធតែកាំភ្លើង ដល់ម៉ោចូល ដល់ហ្នឹង បានយើងនិយាយជាមួយប្រជាជនដែលគាត់កំពុងតែកាប់ព្រៃធ្វើចំការថា ពួកយើងរត់ចេញពីប្រទេសអញ្ចឹង គេក៏គេអត់ធ្វើអីយើងទេ ក៏គេទៅហៅមេគេម៉ោ ដែរថៃហ្នឹង ហៅម៉ោថាខ្មែរយើងធ្វើសង្គ្រាមរត់ចូលម៉ោអញ្ចឹង គេក៏ ។

សេងគា ៖ ថៃហ្នឹងនៅម្តុំណា?

ខុន ៖ ខេត្តចន្ទសូរីហ្នឹងហើយ ប៉ុនយើងមិនដឹងថាម្តុំណា ដឹងតែចន្ទសូរីហ្នឹងហើយ ទៅដល់ក៏ គេហៅយើងចូលម៉ោក្នុងកន្លែងគេ ។

សេងគា ៖ គេអត់មានធ្វើបាបអីទេ?

ខុន ៖ អត់ទេ!អត់មានធ្វើទេ គេគ្រាន់តែហៅយើងម៉ោសួរដំណើរទំនងយើងអញ្ចឹងទៅ គេសួរ ថាម៉េចបានរត់ចេញអីម៉េច ខ្ញុំថាម៉ោពីយើងវ៉ៃគ្នាអញ្ចឹង យើងបែកគ្នារត់វង្វេងព្រៃ វង្វេងផ្លូវអញ្ចឹងទៅ យើងចេះតែម៉ោៗតាមព្រៃ ចេះតែឡើងភ្នំចុះភ្នំ ។

សេងគា ៖ មីងចេះនិយាយថៃដែរ?

ខុន ៖ អត់ខ្ញុំអត់ចេះទេ ។

សេងគា ៖ ម៉េចគេដឹង?

ខុន ៖ គេមានគេ គេចេះដែរ ។

សេងគា ៖ អញ្ចឹង?

ខុន ៖ ចា៎!មានដូចថាគេហ្នឹងគេជាយទៅ គេចេះខ្មែរប៉ៃឡាំមៗអញ្ចឹងទៅ ហើយយើងអត់ទាន់ មានអ្នកណាចេះថៃប៉ុន្មានទេ ហើយដូចមានខ្មែរយើងពី៧៩អីម៉ោ ។

សេងគា ៖ ហើយរត់ទៅ ទៅនៅថៃរហូត?

ខុន ៖ ចា៎!

សេងគា ៖ នៅបានប៉ុន្មានថៃ?

ខុន ៖ ខ្ញុំនៅមិនបានច្រើនខែទេ ហើយខ្ញុំនិយាយដល់នេះក៏ដឹកម៉ោថៃអញ្ចឹង ម៉ោចូលដល់ថៃ កន្លែងទីប្រជុំជនគ្នាយើងមូលរាប់ពាន់នាក់អញ្ចឹងកាលហ្នឹង ដល់នេះគេដកកាំភ្លើងយើង

អស់ហើយ គេថាយើងមាន(AK) មានអេកែ មានកាប៊ីន មានកាំភ្លើង ថៃទាហានថៃ ហ្នឹងគេដកៗពីយើងអស់ហើយ ។

សេងគា ៖ យ៉ាងម៉េចទៀតមីង?

ខុន ៖ ដល់គេដកពីយើងអញ្ចឹងហើយ គេប្រជុំយើងហ្នឹងអត់ឲ្យអ្នកណាមានកាំភ្លើង មានគ្រាប់អីប្រមូលឲ្យគេទាំងអស់ យើងមានប្រមូលឲ្យគេអស់ហើយ ប្រមូលអញ្ចឹងទៅបានគេប្រជុំយើងទៀតហើយ ប្រជុំឲ្យយើងហ្នឹងកុំឲ្យដើរពាសវាលពាសកាលអីអញ្ចឹងទៅ នៅក្នុងខ្សែគេ គេចងខ្សែគេចងខ្សែការពារឲ្យយើងនៅម៉ាំផ្តុំ មិនឲ្យចេញទេ ។

សេងគា ៖ ច្រើនគ្នាម៉ុំហ្នឹង?

ខុន ៖ ចា៎!ម៉ុំហ្នឹងច្រើន រាប់ពាន់នាក់នោះហ្នឹង ។

សេងគា ៖ ភាគច្រើនសុទ្ធតែនាក់?

ខុន ៖ ប្រជាជន ពួកខ្មែរយើងប្រជាជនយើងដែលរត់ចេញម៉ោពីប្រទេសយើងហ្នឹងជាមួយគ្នាចេះតែរត់ម៉ោតាមគ្នីគ្នាអញ្ចឹងទៅ ។

សេងគា ៖ បានប្រហែលជាកន្លះខែ មួយខែទេ?

ខុន ៖ អត់ទេ!អត់បានទេអូន នៅប្រហែលជា២ថ្ងៃជាងហ្នឹងនៅក្នុងថៃ ២ថ្ងៃហ្នឹងក៏គេដកកាំភ្លើងដាក់មួយម៉ុំអញ្ចឹងទៅ ដល់នេះក៏គេសួរយើងមានអីហូប អត់អីហូបគេយកជំនួយមកជួយយើងតាំងពីត្រីខ ទឹកប្រហុក ត្រីអីហ្នឹង នីចំណីយកមកឲ្យយើងហូប អង្ករអីហ្នឹងយកមកឲ្យយើងហូប ហើយដល់នេះបានគេដឹកយើងម៉ោនៅខ្លែមនេះ ដឹកម៉ោដាក់វត្តខ្លែមនេះថៃហ្នឹង នៅហ្នឹងបានប្រហែលម៉ាអាទិត្យដែរ ហ្នឹងក៏គេអត់ឲ្យយើងចេញ ដែរគេអត់ឲ្យយើងចេញពីរង្វង់នៃខ្លែមហ្នឹងទេ ពេលយើងផ្ញូតទឹកផ្ញូតអីយើងមាន ម៉ោងមានម៉ោងគេឲ្យយើងផ្ញូតទឹក ។

សេងគា ៖ បាទ!អញ្ចឹងនៅបានពីរ បីហើយបកម៉ោឬក៏ម៉េច គេបញ្ជូនយើងម៉ោវិញឬក៏ម៉េច?

ខុន ៖ គេបញ្ជូនយើងម៉ោ គេបញ្ជូនយើងម៉ោនៅខ្មែរយើង ។

សេងគា ៖ បាទ!អញ្ចឹងនៅពេលដែលមីងនៅបានពីរ បីគេបញ្ជូនម៉ោវិញឬទៅណា?

ខុន ៖ គេបញ្ជូន ថៃគេបញ្ជូនម៉ោខ្មែរ ។

សេងគា ៖ បញ្ជូនទៅខាងណាវិញ?

ខុន ៖ ម៉ោខែរយើងហ្នឹង ម៉ោនៅខាងដីខ្មែរយើងហ្នឹង នៅម៉ុំអូរជាអូអីនេះ គេបញ្ជូនឲ្យយើងម៉ោក្នុងដីយើងនេះ ម៉ោជាយៗដែនហ្នឹង ។

សេផគា ៈ ដល់គេបញ្ជូនម៉ោ ម៉ោនៅស្រុកខ្មែរនៅខាងណាវិញមីង?

ខុន ៈ នៅហ្នឹងនៅម្តុំហ្នឹងដដែល ។

សេផគា ៈ ម៉ោនៅស្រុកកំរៀងនេះវិញ?

ខុន ៈ ចា៎!កាលហ្នឹងទ័ពយើងចេះតែម៉ោច្រើនៗ នៅហ្នឹងទាំងអស់ ។

សេផគា ៈ ចុះថាក្នុយប្រសារមីងធ្វើអីនៅនេះ?

ខុន ៈ ចា៎!គួរតែហ្នឹង ។

សេផគា ៈ គូរតែហ្នឹង ដល់ពេលម៉ោកន្លែងនេះគេឲ្យមីងធ្វើអី?

ខុន ៈ ខ្ញុំដល់នេះ ខ្ញុំលែងធ្វើអីហើយខ្ញុំលាក់ខ្លួនខ្ញុំលែងធ្វើអីទាំងអស់ អីក៏ខ្ញុំអត់ធ្វើៗដែរ ធ្វើតែនារីដឹកជញ្ជូន ។

សេផគា ៈ ចុះបានស្វាមីនៅឆ្នាំណា?

ខុន ៈ ខ្ញុំបានឆ្នាំមុន៨០ កាលហ្នឹងឆ្នាំ៨០ ។

សេផគា ៈ អញ្ចឹងដល់បានម៉ោដល់នេះហើយបានប្តី?

ខុន ៈ ចា៎!

សេផគា ៈ ស្វាមីឈ្មោះអីគេដែរ?

ខុន ៈ ឈ្មោះ ប៉ុល ផន ។

សេផគា ៈ គាត់ធ្វើអីដែរ?

ខុន ៈ ឥឡូវគាត់នៅខាងអភិវឌ្ឍន៍ស្រុក ។

សេផគា ៈ រាល់ថ្ងៃគាត់នៅធ្វើអញ្ចឹងដដែល?

ខុន ៈ ចា៎!នៅធ្វើរាល់ថ្ងៃហ្នឹង ។

សេផគា ៈ គាត់អ្នកស្រុកណាដែលអ្នកមីង?

ខុន ៈ ស្រុកគាត់នៅតាកែវដែរ ។

សេផគា ៈ ចុះកាលពីសម័យហ្នឹងគាត់ធ្វើអីដែរ?

ខុន ៈ គាត់ធ្វើទ័ពដែរ ។

សេផគា ៈ ធ្វើទ័ពដែរ?

ខុន ៈ ចា៎!កាលហ្នឹងគាត់ពិការភ្នែកម្ខាង ត្រូវគ្រាប់ ។

សេផគា ៈ កាលហ្នឹងគាត់ធ្វើទ័ពនៅណា?

ខុន ៈ ធ្វើទ័ពនៅតាកែវ នៅគាត់ដើរធ្វើការគ្រប់កន្លែងទាំងអស់កាលហ្នឹង ។

សេងគា : ដល់ពេលបានចាប់គ្នា គេរៀបការឲ្យឬក៏រៀបការខ្លួនឯង?

ខុន : ដូចថាគេដណ្ដឹងយើងអញ្ចឹងដែរ គេអត់បង្ខំចិត្តយើងទេ ។

សេងគា : ដល់ពេលគេអត់បង្ខំ គេម៉ោដណ្ដឹងទៅមីងក៏យល់ព្រមទៅ?

ខុន : ចា៎!

សេងគា : ស្រឡាញ់គ្នាដែរ ឬស្រឡាញ់គ្នាមុនហើយ?

ខុន : អត់ស្រឡាញ់មុនទេ មេៗគេអញ្ចឹងដូចថា មេៗគេរៀបចំឲ្យយើងដូចថា ។

សេងគា : កាលហ្នឹងមីងម៉ោខាងណា ម៉ោខាងនាយកនឬម៉េចម៉ោខាងនេះ?

ខុន : មេហ្នឹងខ្ញុំនៅជាមួយឈ្មោះ ខេងៗ ដែលគាត់ គ្រួសារខ្ញុំនៅជាមួយតា១៨ហ្នឹង ។

សេងគា : តា១៨ហ្នឹងឈ្មោះអី?

ខុន : ចៅហ្វាយស្រុក សុខ គង់ ។

សេងគា : អ៊ូ!សុខ គង់?

ខុន : ចា៎!

សេងគា : នៅកន្លែងខេត្ត?

ខុន : ចា៎!ដល់ហើយគាត់សួរជាមួយតា ឃឹម កាលហ្នឹងយើងមកងពលតាឃឹម ហើយដល់តាគង់ គាត់ឲ្យសួរតាមរយៈតាឃឹមហ្នឹងទៅ ហើយតាឃឹមក៏សួរតាមមេខ្ញុំដែលនារីៗអញ្ចឹងទៅណា៎ ហើយខ្ញុំក៏ចេះតែឆ្ងល់ដែរចុះ បងៗម៉េចក៏តាឃឹមគាត់សួររកខ្ញុំអញ្ចឹងតិចអ្នកណាមានបញ្ហាអីវាយការខិលខូចអីពីខ្ញុំ ខ្ញុំអត់ព្រមទេណា៎ គាត់ក៏ថាមិនបាច់ភ័យទេបង ចាំខ្ញុំទៅសួរគាត់ឲ្យ ដល់គាត់ទៅប្រជុំហ្នឹង គាត់ឃឹមថា បង បងឯងសួររកឈ្មោះខុនធ្វើអី? អើអញចេះតែសួរៗទៅហើយម៉េចឥឡូវ គាត់ភ័យណាស់ បងឯងសួរគាត់អញ្ចឹងគាត់ភ័យណាស់មិនដឹងមានអ្នកណាខិលខូចអីវាយការខូចដាក់ អញ្ចឹងគាត់ថាមិនបាច់ភ័យទេ អញសួរដំណឹងពិសេសទេ បងខេងនោះគាត់ទៅប្រាប់ខ្ញុំអញ្ចឹងទៅ ដល់បាន២-៣ថ្ងៃក៏ឲ្យតាគង់ហ្នឹងក៏ឲ្យគ្រួសារខ្ញុំរាល់ថ្ងៃមកសួរចិត្តខ្ញុំម៉ង់ទៅណា៎ ។

សេងគា : បាទ!

ខុន : ចា៎!ខ្ញុំក៏តាមហ្នឹងទៅ ខ្ញុំថានៅផ្ទះម្ដាយទុកដាក់ នៅក្នុងព្រៃស្រេចតែលើមេទុកដាក់ឲ្យទៅតាមមេទៅ ។

សេងគា : មេមីងឈ្មោះ ខេង?

ខុន : ឈ្មោះ ខេងៗ នារី ខ្ញុំក៏តាមគាត់អញ្ចឹងទៅ ។

សេងគា ៖ ការហើយទៅរហូត?

ខុន ៖ ចា៎! រៀបនោះ៥គូរ ។

សេងគា ៖ អ្នកណាខ្លះកាលហ្នឹង?

ខុន ៖ ៥គូរហ្នឹងស្លាប់អស់ហើយគូរៗ នៅតែខ្ញុំទេមួយគូរហ្នឹងទេ មានខ្ញុំ ពូមានយើងហ្នឹង ពូមានហ្នឹងក៏ធ្វើដែរតែគាត់ស្លាប់បាត់ដែរហើយ ហើយមានពូបូរ ពូបូរនៅស្លាប់ប្រពន្ធដែលហើយ ហើយពូវ៉ននោះស្លាប់ប្រពន្ធដែលហើយ នៅតែពូវ៉នទេ ហីបើ ផាំង ខា នោះស្លាប់ទាំង២ហើយឥឡូវនោះ អញ្ចឹង៥គូរហ្នឹងនៅតែខ្ញុំទេមួយគូរហ្នឹង ។

សេងគា ៖ មីងតាំងពី៧៨រហូតដល់៨០អីហ្នឹងអត់ទាន់បានទៅជួបម្ដាយជួបអីទេ?

ខុន ៖ ខ្ញុំបានទៅជួបកាល៧៦អីទេខ្ញុំបានទៅលេងផ្ទះម្ដង ។

សេងគា ៖ ៧៦បានទៅលេងផ្ទះមួយដងកាលនៅស្រែអំបិលនៅឡើយទេ?

ខុន ៖ ចា៎! កាលនៅស្រែអំបិល គេឲ្យទៅ ទៅលេងបានរយៈម៉ោអាទិត្យ ទៅបានមួយដងហ្នឹង ហើយឡើងម៉ោនេះរហូតអត់ដែលបានទៅ រហូតទល់ផ្ដាច់ខ្លួននេះទេបានៗទៅ ។

សេងគា ៖ ផ្ដាច់ខ្លួនឆ្នាំណាមីង?

ខុន ៖ កាលផ្ដាច់ខ្លួនឆ្នាំប៉ុន្មានចាំអត់បានទេ ខ្ញុំមិនសូវយកចិត្តទុកដាក់អាងមិនមែនការងាររបស់ខ្លួន ។

សេងគា ៖ ដល់ពេលអញ្ចឹងទៅផ្ដាច់ខ្លួនទៅ?

ខុន ៖ ចា៎!

សេងគា ៖ ផ្ដាច់ខ្លួនធ្វើអីទៅ?

ខុន ៖ ធ្វើចំការវិញទៅ ។

សេងគា ៖ កាលពីមុននៅទ័ពនៅឡើយទេ ដល់ពេលផ្ដាច់ខ្លួនបានមកធ្វើចំការវិញ?

ខុន ៖ ចា៎! នៅក្នុងទ័ពហ្នឹងក៏ធ្វើចាំការដែរ ចុះប្ដីទៅមុខទៅប្រពន្ធនៅធ្វើដើម្បីទុកបត្តុមទៅប្ដីខ្លះអីខ្លះទៅ គ្នាដូចថាត្រូវការសាប៊ូទិញអីកក់សក់ ថ្នាំដុសធ្មេញអីយើងមានលុយពីណា ។

សេងគា ៖ មីងមានត្រូវបានគេចាប់ចងអ?

ខុន ៖ អត់ទេ ខ្ញុំអត់ដែលទេ ។

សេងគា ៖ ហើយចុះមានឃើញគេធ្វើបាបចាប់ចង?

ខុន ៖ ខ្ញុំក៏អត់ដែលមានឃើញដែល ។

សេងគា ៖ អត់ឃើញទេ?

ខុន ៖ ចា៎!អត់ដែលមានអញ្ចឹងទេ ។

សេងគា ៖ ប៉ុនធ្លាប់ឃើញទាហានត្រូវរបួសអីមាន?

ខុន ៖ ចា៎!ចុះយើងរំគ្នាជាមួយ ដូចថាយើងក្បត់គ្នាទៅវិញទៅម៉ោ ។

សេងគា ៖ បាទ!ប៉ុន្តែការហូបចុកអីអត់អីទេ?

ខុន ៖ អត់អីទេ គ្រាន់តែមធ្យមអត់ខ្វះខាតអីដូចគេទេ ការរស់នៅដូចថាមានអត្តភាព មានអីអញ្ចឹងវាមិនសូវអត់ទេ ដូចខ្ញុំប្រាប់អូនឯងអញ្ចឹង ។

សេងគា ៖ បាទ!

ខុន ៖ ពីខាងលើម៉ោអញ្ចឹង ថាខ្ញុំអត់សូវជួបការលំបាកអីប៉ុន្មានទេ វាស្រួល ខ្លះគេជួប ខ្ញុំអត់សូវអីទេអត់សូវអត់ឃ្លានអីប៉ុន្មានទេ ។

សេងគា ៖ ដល់ពេលរួចទៅមីងម៉ោនៅនេះមានកូនមានចៅរហូតដល់សព្វថ្ងៃនេះទៅ?

ខុន ៖ ចា៎!មានកូនមានចៅទៅ សុខសាន្តរហូតទៅ ។

សេងគា ៖ អញ្ចឹងយើងធ្វើល្អមីង?

ខុន ៖ ចា៎!ធ្វើល្អមែន ទឹកដោះម្តាយថ្លៃ ។

សេងគា ៖ បាទ!ចុះមីងម៉េចបានមីងដឹងថាបងស្រីរបស់មីងស្លាប់អីកាលសម័យហ្នឹង?

ខុន ៖ សម័យហ្នឹងមានដូចថាបងប្អូនយើងអញ្ចឹង ម៉ោលេងអញ្ចឹងទៅខ្ញុំសួរតាមគេ ។

សេងគា ៖ បងប្អូនអ្នកណាគេ?

ខុន ៖ ដូចថាបងប្អូនឲ្យតែពូថាគ្នានៅណានៅ៣២យើងនេះនុ៎ះ ។

សេងគា ៖ ឈ្មោះអីបងប្អូន?

ខុន ៖ ឈ្មោះ តាជា តាជាហ្នឹងគាត់ម៉ោ គាត់ម៉ោរកលេងកូនអញ្ចឹងទៅៗខ្ញុំក៏ថាផ្ញើរសំបុត្រទៅតាមម៉ែមីទូចខ្ញុំ ហើយបងថ្លៃខ្ញុំហ្នឹងគាត់ម៉ោរកខ្ញុំដែរ គាត់ដឹងថាប្អូននៅហើយ ខ្ញុំចេះតែផ្ញើរដំណឹងទៅក៏គាត់ម៉ោរក ដល់គាត់ម៉ោរកអញ្ចឹងទៅ ខ្ញុំក៏ ។

សេងគា ៖ កាលហ្នឹងឆ្នាំណាមីងផ្ញើរសំបុត្រហ្នឹង?

ខុន ៖ ខ្ញុំភ្លេចឆ្នាំហើយ នៅក្នុងសង្គ្រាមយួនអីវៃគ្នា ដល់គាត់ម៉ោលេងអញ្ចឹងគាត់នៅ៣២ យើងបៀតកូនជីវិស្វាយសុំសុផុនណាអូន ហើយដល់ហើយគេបិទផ្លូវអត់ឲ្យគាត់ម៉ោទេ ដល់អត់ឲ្យគាត់ម៉ោអញ្ចឹងក៏គាត់ផ្ញើរសំបុត្រម៉ោ ដល់ផ្ញើរសំបុត្រម៉ោឃើញឈ្មោះគាត់ ហ្នឹងខ្ញុំក៏សុំពូ១៨នេះ ។

សេងគា ៖ ពូ១៨ហ្នឹងអ្នកណាគេ?

ខុន : តាគន់ហ្នឹង ។

សេងគា : អ្ហូ!ពូ១៨ហៅតាគន់?

ខុន : ចា៎!

សេងគា : ម៉េចបានគេហៅពូ១៨?

ខុន : លេខគាត់ លេខ១៨នោះ ។

សេងគា : លេខ១៨ហ្នឹងអីគេ?

ខុន : លេខមន្ទីរគាត់ គេហៅថាតា១៨ៗហ្នឹង ។

សេងគា : មានប៉ុន្មាននខ្លះ អា១១-១២មានឬទេ?

ខុន : មាន១៧អញ្ចឹងទៅ មាន១៦អញ្ចឹងទៅ ។

សេងគា : ១៧អ្នកណាគេ?

ខុន : ១៧ វ៉ែតនិយាយម៉េចហ្នឹង ហើយដូចតាបែនោះ១៦អញ្ចឹងទៅ ។

សេងគា : តាបែ ហ្នឹងគាត់ធ្វើអីគេ?

ខុន : តាបែហ្នឹងក៏គាត់ធ្វើនៅកងពលដែរ ។

សេងគា : កងពលដែរ ឥឡូវគាត់ធ្វើកងពលដែរ?

ខុន : ឥឡូវមិនដឹងគាត់ធ្វើអីទេ ។

សេងគា : គួរ វ៉ែតគាត់នៅកងពលនៅឡើយទេ?

ខុន : គួរវ៉ែតគាត់នៅកងពល ប៉ុនឥឡូវគាត់ស្លាប់ គាត់ឈឺ ។

សេងគា : ហើយអ្នកណាគៀត?

ខុន : វាច្រើនអូនរាប់មិនអស់ទេ ។

សេងគា : មានលេខគេអញ្ចឹង?

ខុន : ចា៎!មានលេខគេអញ្ចឹង ។

សេងគា : ប៉ុន្តែទាំងអស់ហ្នឹងសុទ្ធតែមេធំៗ?

ខុន : ចា៎!សុទ្ធតែមេគេ ។

សេងគា : ហើយចុះនៅពេលដែលផ្ញើរសំបុត្រចុះឡើងៗទៅ គាត់មានប្រាប់ថាបងមឹងស្លាប់ដែរ?

ខុន : ចា៎!ដឹងដំណឹងអញ្ចឹងទៅ ក៏បងថ្លៃខ្ញុំម៉ោក៏ផ្ញើរសំបុត្រទៅគាត់ឲ្យទៅរកម៉ែឪខ្ញុំទៅ បាន ទៅរកម៉ែឪគាត់ទៅរកឃើញ គាត់នៅជិតផ្ទល់បត់យើងបៀនសង្កសីក្រាំងស្នានោះណា៎ បងខ្ញុំថាគាត់នៅក្បែរសៃវ៉ាចុះម៉ោបន្តិចទៅ ក៏ដើរសួររកឃើញ ។

សេងគា ៖ បងថ្លៃឈ្មោះអីមីង?

ខុន ៖ បងថ្លៃខ្ញុំឈ្មោះ ផុន ។

សេងគា ៖ ឈ្មោះ ផុន?

ខុន ៖ ចាំ!គាត់មកលេងបង២នាក់ ផុន ហើយភីហ្នឹងគាត់ម៉ោ ដល់ហើយគាត់រកឃើញខ្ញុំក៏ផ្ញើរលុយទៅឲ្យតាមគាត់ហ្នឹងទៅ ។

សេងគា ៖ ចុះម៉េចបានដឹងថាស្លាប់ គាត់ប្រាប់?

ខុន ៖ គាត់ប្រាប់ ដល់នេះគាត់ផ្ញើរសំបុត្រម៉ោ ។

សេងគា ៖ ប្រាប់ថាស្លាប់ម៉េចខ្លះទៅ?

ខុន ៖ ចាំ!គាត់ស្លាប់ហ្នឹង គាត់ស្លាប់ឈឺចាស់ ។

សេងគា ៖ ឪពុក ឬម្ដាយ?

ខុន ៖ ម្ដាយឈឺចាស់ទេ ។

សេងគា ៖ ឆ្នាំ៨០ជាងហើយ?

ខុន ៖ ឆ្នាំមុនយើងដាច់ខ្លួនបន្តិច ។

សេងគា ៖ អ្ហូ!៨០ជាង៩០ហើយ?

ខុន ៖ ចាំ!ដល់នេះគាត់ស្លាប់ទៅ បាននេះបានខ្ញុំទៅផ្ទះនាំទៅលេង នាំទៅលេងជាមួយគាត់ទៅជួបតែបងទេ បងហើយក្មួយទេ ក្រៅពីហ្នឹងគេស្លាប់បាត់អស់ហើយ ខ្ញុំទៅទៅធ្វើបុណ្យធ្វើអីទៅ ធ្វើបុណក៏មិនធ្វើធំដែរ កាលហ្នឹងយើងទឹមដាច់ខ្លួនហើយ យើងក៏មិនទាន់មានលុយប៉ុន្មានទេអូន មានតែទឹម៣-៤ពាន់បាតហ្នឹងឯង ។

សេងគា ៖ បាទ!

ខុន ៖ ចាំ!ធ្វើបុណ្យឲ្យគាត់បានម្ដង ដល់យើងមានផ្លូវមានអីស្រួលនេះបានទៅម្ដងទៀត ។

សេងគា ៖ ម្ដងហ្នឹងជួបឪពុកទេ?

ខុន ៖ អត់ជួបទេ!ឪពុកខ្ញុំស្លាប់មុនហើយហ្នឹង ។

សេងគា ៖ ចុះឪពុកស្លាប់មុន?

ខុន ៖ ស្លាប់តាំងពីមិនទាន់កើតសង្គ្រាមនោះ យើងនៅសុខសាន្ត ។

សេងគា ៖ តាំងពី៦០ជាងឬក៏នៅ៧០ជាង?

ខុន ៖ តាំងពីនៅ៧០ជាងនោះ ។

សេងគា ៖ ម្ដាយទើបតែស្លាប់ទេ?

ខុន ៖ ចាំ!

សេងគា ៖ ចុះគាត់មានប្រាប់ថាបងស្លាប់ដោយសារអីទេ?

ខុន ៖ ថាវាឈឺពេលរត់ទៅ វាអត់ឃ្លានអីញ៉ាំងទៅ ។

សេងគា ៖ ចុះបងទី២វិញ?

ខុន ៖ បងទី២គាត់នៅរស់រាល់ថ្ងៃហ្នឹង ។

សេងគា ៖ គាត់នៅតាកែវ?

ខុន ៖ ចាំ!នៅផ្ទះតាកែវ ។

សេងគា ៖ គាត់អត់អីដែរ?

ខុន ៖ ចាំ!អត់អីទេ ។

សេងគា ៖ ហើយរាល់ថ្ងៃដែលបានជួបគ្នាញឹកទេ?

ខុន ៖ បងហ្នឹង?

សេងគា ៖ បាទ!

ខុន ៖ ជួប ជួបតេម៉ោរាល់ថ្ងៃដែរ មិនសូវញឹកដែរ ។

សេងគា ៖ ហើយពេលជំនាន់ហឹងមកដល់សព្វថ្ងៃនេះ អ៊ំមានជួបរឿងរ៉ាវអីដែលអ៊ំគិតថាឈឺចាប់ជាងគេអី ជួបកាលពីសម័យមុនរហូតដកដល់ឥឡូវទេ?

ខុន ៖ កាលហ្នឹងអូនអើយ យើងមិនសូវជាឈឺអីប៉ុន្មានទេ គ្រាន់តែយើងស្មគ្រចិត្តដោយខ្លួនឯងទេ ។

សេងគា ៖ ចុះអ៊ំអត់មានស្តាយក្រោយ ពីការស្មគ្រចិត្តរឿងធ្វើទ័ពធ្វើអីហ្នឹងទេ?

ខុន ៖ អត់ៗអត់ដែលទេ ។

សេងគា ៖ ហើយអត់មាននឹកឃើញក្នុងចិត្ត ឈឺចិត្តពីរឿងរ៉ាវណា?

ខុន ៖ អត់ ព្រោះយើងអត់មានជួបប្រទះការលំបាកអីថាគេធ្វើបាបធ្វើអីយើង ។

សេងគា ៖ ដូចជាស្រួលរហូតដែរ?

ខុន ៖ ចាំ!ដូចជាស្រួលរហូត ខ្លះគេជួបប្រទះគេខូចចិត្ត ។

សេងគា ៖ ខ្លះអត់អីហូប?

ខុន ៖ ចាំ!អត់អីហូប ហើយគេធ្វើបាប គ្រប់បែបយ៉ាងដូចថាគេបិទសិទ្ធិយើង ហើយខ្ញុំគេវាអត់មានអ្នកណាបិទសិទ្ធិខ្ញុំទេ ខ្ញុំធ្វើអីក៏ៗអត់ជួបប្រទះនឹងការលំបាកចេះតែស្រួលរហូតដូចថាជួបតែអ្នកល្អ មិនដែលមានជួបអីខុសគ្គអីដូចថា គេស្តីឲ្យយើងចេះចុះមួយអត់ ទេ

មានតែគេស្រឡាញ់យើង ទៅនេះទៅនោះគេយកយើងទៅតាមរហូតអញ្ចឹងទៅ ខ្ញុំអត់ដែលមានការជួបប្រទះវេទនាអី អត់ទេ ។

សេងគា ៈ បាទ!ហើយឥឡូវជួបមេៗទៀតមានអារម្មណ៍យ៉ាងម៉េចដែរ ?

ខុន ៈ ជួបមេៗយើងហ្នឹង?

សេងគា ៈ បាទ!

ខុន ៈ មានអារម្មណ៍ថានឹកគ្នា បែកគ្នាអនុស្សាវរីយ៍យើងពីមុនម៉ោហ្នឹង ។

សេងគា ៈ មេហ្នឹងស្គាល់មីងទេ?

ខុន ៈ ស្គាល់ ។

សេងគា ៈ មានហៅអីទៅធ្វើការជាមួយគាត់វិញទេ?

ខុន ៈ ហ៊ឺ!ហៅក៏ខ្ញុំអត់ធ្វើដែរ ហួសពេលហើយ ។

សេងគា ៈ បាទ!អ៊ីដូចអស់ពាក្យអីត្រូវសួរអ៊ី ជាចុងក្រោយអ៊ីមានពាក្យអីចង់បន្ថែម ចង់និយាយទេ?

ខុន ៈ ខ្ញុំអត់មានអីបន្ថែមទៀតទេ ។

សេងគា ៈ អញ្ចឹងអ៊ីមានលេខទូរស័ព្ទទេ ខ្ញុំអាចសុំលេខទូរស័ព្ទអ៊ីបានទេ?

ខុន ៈ ខ្ញុំអត់ដែលប្រើទូរស័ព្ទទេ មានតែគ្រួសារ ។

សេងគា ៈ អ្ហូ!មានតែគ្រួសារ លេខគ្រួសារហ្នឹងលេខអី?

ខុន ៈ ចាំ!ទាល់តែទៅសួរប្រធានភូមិ ខ្ញុំអត់ចាំទេ ។

សេងគា ៈ ហើយចុះលេខកូនអត់មានទេ?

ខុន ៈ លេខកូនក៏មានដែរ តែខ្ញុំអត់ចាំ ។

សេងគា ៈ បានជាខ្ញុំចង់សួររកលេខនេះ កាលណាខ្ញុំខ្វះពត៌មានបន្ថែមខ្ញុំសួរតាមលេខទូរស័ព្ទអ៊ី អញ្ចឹង ព្រោះខ្ញុំឃើញមីងជាប្រធានសហករណ៍ ប៉ុន្តែចិត្តល្អ ខ្ញុំចង់សរសេរជាអត្ថបទមួយដូចក្នុងសៀវភៅនេះអញ្ចឹង ។

ខុន ៈ ចាំ!

សេងគា ៈ ចាំខ្ញុំចុះបានចាំខ្ញុំផ្ញើរជូនមីងមើល?

ខុន ៈ ចាំ!ខ្ញុំជួបតែល្អមែន ខ្ញុំដើចជាមួយប្រជាជនក៏ខ្ញុំជួបតែល្អ គាត់គ្មានធ្វើបាបអីយើងអត់ទេស្រួលណាស់ ខ្ញុំដើរទៅដេកនៅក្នុងព្រៃក្នុងផ្សេរអីជាមួយមាក្រុមពីរក្រុមអីតែកាំ

ភ្លើងមួយដើមហ្នឹងខ្ញុំអត់មានទេ អត់មានអ្នកណាធ្វើបាបខ្ញុំទេ អ្នកខ្លះឃើញយើងដើរតែឯងគេចង់ធ្វើឃាតយើង នេះអត់ទេ ។

សេងគា ៖ ចុះបើ និយាយឲ្យចំបើអ៊ំអត់មានធ្វើអីអាក្រក់ផង?

ខុន ៖ អត់មានទេ ខ្ញុំគិតទៅខ្ញុំដើរទៅតែឯងៗ ប្រជាជននៅកន្លែងណាខ្ញុំដើរទៅកន្លែងហ្នឹង ខ្ញុំមានកាំភ្លើងតែមួយដើមទេខ្ញុំ ។

សេងគា ៖ ចុងក្រោយមួយទៀត ខ្ញុំចង់សួរអ៊ំដែរទាក់ទងដូចថាឥឡូវមានតុលាការមានអីហ្នឹងកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗអញ្ចឹង បើតាមយោបល់អ៊ំផ្ទាល់អ៊ំយល់យ៉ាងម៉េចដែរ?

ខុន ៖ ធ្វើម៉េចអាហ្នឹងតាមច្បាប់របស់គេ ។

សេងគា ៖ អ៊ំអត់ខឹងអត់អីទេ?

ខុន ៖ ធ្វើម៉េច ដូចថាយើងមិនអាចទៅដល់ជាមួយថ្មបានទេ យើងពងមាន់ខ្ញុំនឹកក្នុងចិត្តអញ្ចឹងអូនណា៎ ស្រេចតែគេវិនិច្ឆ័យតាមហ្នឹងទៅ ។

សេងគា ៖ ព្រោះនៅក្នុងនេះគេកាត់ទោសតែអ្នកធំៗទេមានដូចជាប៉ុល ពត ខៀវ សំផន អៀង សារី ឥឡូវហ្នឹងកំពុងតែនៅក្នុងឃុំ?

ខុន ៖ ចា៎!

សេងគា ៖ ប៉ុល ពត ស្លាប់ហើយ?

ខុន ៖ ស្លាប់ហើយ តាម៉ុកក៏គាត់ស្លាប់ដែរ ។

សេងគា ៖ អញ្ចឹងសល់តែនាក់ធំៗប៉ុន្មាននាក់ហ្នឹង អញ្ចឹងអ៊ំយល់ឃើញយ៉ាងម៉េចដែរមានតុលាការកាត់ទោសកាត់អីអញ្ចឹង?

ខុន ៖ ដូចខ្ញុំនិយាយមិញអញ្ចឹងអូន ស្រេចតែលើគេទេ កាត់តាមច្បាប់គេទៅ ព្រោះខ្ញុំរស់ក៏ក្រោមការដឹកនាំរបស់ច្បាប់ ចា៎!អានេះដូចថាគេចូលទៅដល់សង្គមមួយៗ ហើយយើងរស់នៅតាមការដឹកនាំរបស់សង្គម ចា៎!សង្គមណាគេដឹកនាំទៅផ្លូវណាយើងទៅផ្លូវហ្នឹងទៅ មិនអញ្ចឹងអូន?

សេងគា ៖ បាទ!

ខុន ៖ ចា៎!ឥឡូវដូចឧទាហរណ៍ថា គណបក្សយើងចុះ យើងនិយាយឧទាហរណ៍ គេភាគណាគេទៅខាងណាច្រើនយើងចេះតែទៅតាមគេ អាហ្នឹងខ្ញុំនិយាយអញ្ចឹង ។

សេងគា ៖ រាល់ថ្ងៃអ៊ំគិតថាសុំតែសុខលែងគិតអីហើយ?

ខុន : ចា៎!ខ្ញុំសុំតែសុខ ខ្ញុំលែងគិតអីអស់ហើយ ព្រោះថាកន្លែងណាគេឲ្យយើងនៅសុខ យើងនៅសុខទៅ យើងនៅក្រោមការដឹកនាំរបស់រដ្ឋ ធម្មតាយើងត្រង់ណាយើងនៅបានសុខយើងចេះតែនៅទៅ យើងអត់អាចប្រឆាំងបាន ខ្ញុំណែនាំកូនខ្ញុំក៏ខ្ញុំនិយាយអញ្ចឹងដែរថាកូនអើយ ទោះបីយ៉ាងណាក៏ដោយកន្លែងណាម៉ែឪយើងតែងតែណែនាំទេ ឲ្យតែក្រកូនណា៎ងើបស្ទុក ។

សេងគា : ហើយផ្ទះក្មួយប្រសារអ៊ំឈ្មោះរ៉េត ហ្នឹងដឹកយកទៅណាទៅ?

ខុន : នៅជិតគ្នាហ្នឹងដែរ ។

សេងគា : គាត់ឈ្មោះ អ៊ីរ៉េត?

ខុន : ជីតាគាត់?

សេងគា : បាទ!

ខុន : អត់ស្គាល់ឈ្មោះគាត់ផង អត់ស្គាល់តាគេ ។

សេងគា : ប៉ុន្តែដឹងថាគាត់ជាវរៈសេនាធំ ប្រធាន?

ខុន : ចា៎!ដឹកថាគាត់ជាអ្នកដឹកនាំគេហ្នឹង ។

សេងគា : អាចមានពេលចង់ទៅជួបសម្ភាសន៍គាត់ដែរ?

ខុន : (សើច) សម្ភាសន៍ប្រពន្ធគាត់?

សេងគា : បាទ!អញ្ចឹងអត់អីទេ អរគុណអ៊ំច្រើន ។

ខុន : ដែលខ្ញុំនិយាយទាំងប៉ុន្មានមានការខុសឆ្គង អនុគ្រោះទៅវាចាំតិចភ្លេចច្រើនហើយ ។

សេងគា : បាទ!មិនអីទេ ព្រោះរឿងហ្នឹងវាច្រើនឆ្នាំហើយ ៣០-៤០ឆ្នាំហើយ ៣០ឆ្នាំជាង ហើយមានអ្នកណាចាំអស់ ចាំបានប៉ុនហ្នឹងគឺអ៊ំចាំច្រើនណាស់ ។

ខុន : ចា៎!ព្រោះខ្ញុំ មនុស្សខ្ញុំអត់ចេះអក្សរទេ អត់ចេះសុទ្ធម៉ង គំឡូងទេអត់ចេះ ។

សេងគា : ប៉ុន្តែអ្នកអត់ចេះអក្សរម៉ាគគោកដែរ សម័យនោះធ្វើបាបប្រជាជនអីច្រើនណាស់ ដូចជានៅខាងសៀមរាប ខាងអីហ្នឹងគេធ្វើបាប សម្លាប់ច្រើនណាស់ តែអ៊ំអត់ចេះអក្សរ អ៊ំអត់បានសម្លាប់គេទេ?

ខុន : ចា៎!ខ្ញុំអត់មានទេ ។

សេងគា : អញ្ចឹងចិត្តយើងបានស្ងប់?

ខុន : ចា៎!អត់មានទេ ខ្ញុំមិនដែលទៅរើបងប្អូនណា មិនដែលមាត់ធ្ងន់ដាក់លើបងប្អូនទេទេ ។

សេងគា : បាទ!ថ្ងៃនេះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១ អញ្ចឹងអរគុណអ៊ំច្រើន ខ្ញុំជំរាបលា ហើយ ។

ខុន ៖ ចាំ!

**ចប់**